# ធនាគារជាតិ នៃកម្ពុជា








# ២០១៥






# របាយការណ៍ប្រចាំឆ្នាំ

## អគ្គនាយកដ្ឋានត្រួតពិនិត្យ



# អារម្ភកថា

សេដ្ឋកិច្ចកម្ពុជា មានកំណើនជាមធ្យមប្រមាណ ៧% នៅក្នុងឆ្នាំ២០១៥ ហើយនឹងរំពឹងថាបន្តមានកំណើនក្នុងរង្វង់ដដែលនេះនៅឆ្នាំ២០១៦ ទោះបីជា កំណើនសេដ្ឋកិច្ចពិភពលោក និងក្នុងតំបន់មានការប្រឈមខ្លះៗក៏ដោយ ។ វិស័យសំខាន់ៗដែលគាំទ្រដល់កំណើនសេដ្ឋកិច្ច រួមមាន វិស័យទេសចរណ៍ ពាណិជ្ជកម្ម សំណង់ និងកាត់ដេរសំលៀកបំពាក់ ខណៈដែលវិស័យកសិកម្មបន្តមានកំណើនយឺត ។ ទន្ទឹមនេះ ប្រទេសកម្ពុជាបានធ្វើកំណែទម្រង់លើគ្រប់វិស័យ ដើម្បីត្រៀមខ្លួនរួចរាល់សម្រាប់ការបំពេញមុខងារនិងភារៈកិច្ចក្នុងសមាហរណកម្មអាស៊ាន ហើយជាពិសេសសំដៅដល់ការពង្រឹងម៉ាក្រូសេដ្ឋកិច្ច និងស្ថិរភាពហិរញ្ញវត្ថុ ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។ ដោយយល់ឃើញពីភាពរឹងមាំនៃប្រតិបត្តិការធនាគារ និងភាពធននៃប្រព័ន្ធធនាគារ វិនិយោគិនក្នុងស្រុក និងក្រៅប្រទេសបានពង្រីកការវិនិយោគរបស់ខ្លួន ដែលជំរុញវិស័យនេះឲ្យដើរតួនាទីកាន់តែសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ តាមរយៈការផ្តល់សេវាហិរញ្ញវត្ថុកាន់តែទូលំទូលាយទូទាំងប្រទេស ។

ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជា បានពង្រឹងនិងពង្រីកទាំងទំហំនិងវិសាលភាពលើការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីទប់ស្កាត់និងការពារការកើតឡើងនៃហានិភ័យដែលអាចកើតមានស្របតាមការវិវត្តយ៉ាងឆាប់រហ័សនៃវិស័យហិរញ្ញវត្ថុ ។ ទន្ទឹមនេះ វិធីសាស្ត្រនៃការត្រួតពិនិត្យត្រូវបានពង្រឹងតាមរយៈការផ្លាស់ប្តូរពីការត្រួតពិនិត្យផ្អែកលើបទប្បញ្ញត្តិ ទៅជាការត្រួតពិនិត្យផ្អែកលើហានិភ័យ និងទស្សនៈអនាគត ដោយផ្តោតជាសំខាន់លើប្រសិទ្ធភាពនៃប្រតិបត្តិការ និងកម្រិតហានិភ័យរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។ ធនាគារជាតិនៃកម្ពុជា យកចិត្តទុកដាក់ខ្ពស់ក្នុងការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដោយផ្តោតលើចំណុចសំខាន់ៗ រួមមាន ៖ ភាពគ្រប់គ្រាន់នៃដើមទុន គុណភាពទ្រព្យសកម្ម ស្ថានភាពសន្ទនីយភាព អភិបាលកិច្ចនិងការត្រួតពិនិត្យផ្ទៃក្នុង និងភាពប្រែប្រួលនៅលើទីផ្សារ ដែលអាចប៉ះពាល់ដល់ប្រតិបត្តិការគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។ ការអនុវត្តការងារត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព សម្រេចទៅបានអាស្រ័យលើសមត្ថភាពរបស់មន្ត្រីត្រួតពិនិត្យ ក្នុងការវាយតម្លៃលើសុខភាពនិងភាពរឹងមាំនៃគ្រឹះស្ថាននីមួយៗ ក៏ដូចជាប្រព័ន្ធធនាគារទាំងមូល ព្រមទាំងចាត់វិធានការកែតម្រូវ និងទប់ស្កាត់ហានិភ័យបានសមស្របនិងទាន់ពេលវេលា ។ ដូចនេះ ការយកចិត្តទុកដាក់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីត្រួតពិនិត្យ ទាំងចំណេះដឹង ជំនាញ និងទ្រឹស្តី គឺជាការចាំបាច់ ដើម្បីធានាបាននូវការត្រួតពិនិត្យប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ ។

ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច នយោបាយ និងសន្តិសុខសង្គម គឺជាកំលាំងចលករសំខាន់ជំរុញដល់ការអភិវឌ្ឍនៃប្រព័ន្ធធនាគារទាំងមូល ។ ធនាគារជាតិនៃកម្ពុជា បន្តពង្រឹងប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយរូបិយវត្ថុ ការរក្សាស្ថិរភាពថ្លៃ ការធានាស្ថិរភាពហិរញ្ញវត្ថុ និងបរិយាប័ន្នហិរញ្ញវត្ថុ ដើម្បីគាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលកម្ពុជា ។ ក្នុងន័យនេះ ការជំរុញការប្រើប្រាស់ប្រាក់រៀល ការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ ការបង្កើនកិច្ចការពារអតិថិជន និងការពង្រឹងការយល់ដឹងរបស់សាធារណជនអំពីផលិតផលនិងសេវាហិរញ្ញវត្ថុ ត្រូវបានកំណត់ជាអាទិភាព ។ ខ្ញុំសង្ឃឹមថា របាយការណ៍នេះ នឹងអាចប្រើប្រាស់ជាឯកសារសម្រាប់បង្កើនការយល់ដឹងដល់អ្នកសិក្សាស្រាវជ្រាវ ក៏ដូចជាផ្តល់ព័ត៌មានដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីស្វែងយល់ពីលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តការងាររបស់ខ្លួន ។

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦

**ជា ចាន់តូ**

**ទេសាភិបាល ធនាគារជាតិនៃកម្ពុជា**

# មាតិកា


អារម្ភកថា ............ i

បញ្ជីរូបភាពនិងតារាង ............ iii

១. ការអភិវឌ្ឍសំខាន់ៗនៃវិស័យធនាគារ ............ ១

១.១. និន្នាការទូទៅនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ............ ១

១.២.ស្ថានភាពនិងប្រតិបត្តិការហិរញ្ញវត្ថុ ............ ៤

១.២.១. ប្រតិបត្តិការនៃវិស័យធនាគារ ............ ៤

១.២.២. ប្រតិបត្តិការនៃវិស័យមីក្រូហិរញ្ញវត្ថុ ............ ៦

១.២.៣. ប្រតិបត្តិការនៃវិស័យភតិសន្យាហិរញ្ញវត្ថុ ............ ៨

២. ការវិវឌ្ឍក្របខណ្ឌនៃការត្រួតពិនិត្យនិងបទប្បញ្ញត្តិ ............ ៨

២.១. ការពិនិត្យឡើងវិញ និងការដាក់ចេញនូវបទប្បញ្ញត្តិ ............ ៨

២.១.១. ការតម្កល់ប្រាក់បម្រុងកាតព្វកិច្ច និងវិធានម៉ាក្រូប្រុងប្រយ័ត្នផ្សេងៗ ............ ៩

២.១.២.ការផ្តល់សន្ទនីយភាពបន្ទាន់ចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ............ ៩

២.១.៣. ការចែករំលែកព័ត៌មានត្រួតពិនិត្យរវាងអាជ្ញាធរត្រួតពិនិត្យ ............ ១០

២.១.៤. ការធ្វើបច្ចុប្បន្នកម្មបទប្បញ្ញត្តិសន្ទនីយភាព ............ ១០

២.២.សកម្មភាពនៃការត្រួតពិនិត្យ ............ ១១

៣. ការជម្រុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនិងសមាហរណកម្មក្នុងតំបន់ ............ ១១

៣.១. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ ............ ១១

៣.១.១.ស្តង់ដារគណនេយ្យនិងរបាយការណ៍ហិរញ្ញវត្ថុ ............ ១១

៣.១.២. ការិយាល័យព័ត៌មានឥណទានកម្ពុជា ............ ១២

៣.១.៣.ប្រតិបត្តិការប្រព័ន្ធទូទាត់ ............ ១២

៣.២.ការអនុវត្តការងារបរិយាប័ន្នហិរញ្ញវត្ថុ ............ ១៣

៣.៣. ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន ............ ១៥

៣.៤. ការផ្តល់ហិរញ្ញប្បទានវិស័យកសិកម្មនិងអចលនទ្រព្យ ............ ១៥

៣.៥. ការកសាងសមត្ថភាពមន្ត្រីត្រួតពិនិត្យ ............ ១៦

៣.៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ ............ ១៧

បញ្ជីឧបសម្ព័ន្ធ ............ ១៩

# បញ្ជីរូបភាព និងតារាង

រូបភាព១: រចនាសម្ព័ន្ធប្រព័ន្ធធនាគារនៅកម្ពុជា........................................................................................១

តារាង១: បណ្តាញនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុពីឆ្នាំ២០១២-២០១៥..................................................................២

តារាង២: ចំណែកទីផ្សារនៃគ្រឹះស្ថានធនាគារតាមភាគទុនិក ................................................................................៣

តារាង៣: ការវិវត្តក្នុងវិស័យធនាគារ (កំណើនឆ្នាំលើឆ្នាំ) ..........................................................................................៤

រូបភាព២: ធនាគារ-ចំនួនអ្នកខ្ចីប្រាក់និងអ្នកដាក់ប្រាក់បញ្ញើ...............................................................................៤

រូបភាព៣: ធនាគារ-ឥណទាននិងប្រាក់បញ្ញើទៅអតិថិជន ......................................................................................៤

រូបភាព៤: ធនាគារ–ឥណទានតាមវិស័យសេដ្ឋកិច្ច ..................................................................................................៥

រូបភាព៥: ធនាគារ–អនុបាតឥណទានមិនដំណើរការ ..........................................................................................៥

រូបភាព៦: មីក្រូហិរញ្ញវត្ថុ-កំណើនទ្រព្យសកម្ម ..........................................................................................................៧

រូបភាព៧: មីក្រូហិរញ្ញវត្ថុ-ឥណទានតាមវិស័យសេដ្ឋកិច្ច.......................................................................................៧

រូបភាព៨: មីក្រូហិរញ្ញវត្ថុ--ឥណទាននិងប្រាក់បញ្ញើ...................................................................................................៧

រូបភាព៩: មីក្រូហិរញ្ញវត្ថុ--គុណភាពសំពៀតឥណទាន .........................................................................................៧

តារាង៤: វិស័យគតិសន្យាហិរញ្ញវត្ថុ .........................................................................................................................៨

រូបភាព១០: ចំនួនការិយាល័យនិងម៉ាស៊ីនអេធីអឹមធៀបនឹងប្រជាជន ១០០.០០០នាក់ ..................................១៤

រូបភាព១១: ភាគរយអ្នកដាក់ប្រាក់បញ្ញើនិងអ្នកខ្ចីប្រាក់ជាស្ត្រីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ...............................១៤

# ទិន្នន័យទាំងអស់មិនទាន់ធ្វើសវនកម្ម និងត្រូវបានរាយការណ៍ដោយ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

## ១. ការអភិវឌ្ឍសំខាន់ៗនៃវិស័យធនាគារ

### ១.១. និន្នាការទូទៅនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ទន្ទឹមនឹងការរីកចម្រើននៃសេដ្ឋកិច្ច ប្រព័ន្ធធនាគារនៅកម្ពុជា បានអភិវឌ្ឍជាបន្តបន្ទាប់ទៅតាមការវិវត្តនៃទីផ្សារ ។ គិតត្រឹមខែធ្នូ ឆ្នាំ២០១៥ ប្រព័ន្ធធនាគារនៅកម្ពុជារួមមាន ៖ ធនាគារពាណិជ្ជចំនួន ៣៦ (ក្នុងនោះមានធនាគារក្នុងស្រុកចំនួន ១២ ធនាគារបុត្តសម្ព័ន្ធចំនួន ១៤ និងសាខាធនាគារបរទេសចំនួន១០) ធនាគារឯកទេសចំនួន ១១ (ក្នុងនោះមានធនាគារឯកទេសចំនួន ១ ជារបស់រដ្ឋ) គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ៥៨ (ក្នុងនោះគ្រឹះស្ថានចំនួន ៨ ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើពីសាធារណជន) ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុចំនួន ១០៩ ការិយាល័យតំណាងធនាគារបរទេសចំនួន ៨ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុចំនួន ៩ អ្នកដំណើរការតតិយភាគីចំនួន ៦ ក្រុមហ៊ុនក្រេឌីតប្យូរ៉ូចំនួន ១ និងអាជីវករប្តូរប្រាក់ចំនួន ២.០១០ (រូបភាព ១)។

រូបភាព១: រចនាសម្ព័ន្ធប្រព័ន្ធធនាគារនៅកម្ពុជា



តារាង១: បណ្តាញនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ[1]ពីឆ្នាំ២០១២-២០១៥

| គ្រឹះស្ថានធនាគារ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|---|
| **ធនាគារពាណិជ្ជ** | | | | |
| **ធនាគារក្នុងស្រុក– ភាគទុនិកភាគច្រើនជាអ្នកក្នុងស្រុក** | | | | |
| ចំនួនធនាគារ | ៦ | ៦ | ៧ | ៧ |
| ចំនួនសាខា | ២៩៨ | ៣១០ | ៣៥៤ | ៣៧៥ |
| ចំនួនបុគ្គលិក | ៩.៦៧៣ | ១១.៧៩៣ | ១៤.៨៩៦ | ១៦.២៣៩ |
| ចំនួនទីតាំងម៉ាស៊ីន ATM | ២៩៥ | ៣២៧ | ៤៥៤ | ៥៤៤ |
| **ធនាគារក្នុងស្រុក– ភាគទុនិកភាគច្រើនជាជនបរទេស** | | | | |
| ចំនួនធនាគារ | ៦ | ៥ | ៦ | ៥ |
| ចំនួនសាខា | ៤០ | ៣៣ | ៤៧ | ៥៤ |
| ចំនួនបុគ្គលិក | ១.០០៩ | ១.០០០ | ១.៤៤៤ | ១.៧៣៨ |
| ចំនួនទីតាំងម៉ាស៊ីន ATM | ១៤៥ | ៧៧ | ១១៧ | ១៧៥ |
| **ធនាគារបុត្តសម្ព័ន្ធបរទេស** | | | | |
| ចំនួនធនាគារ | ១១ | ១៤ | ១២ | ១៤ |
| ចំនួនសាខា | ៩៧ | ១២៨ | ១១៩ | ១៤២ |
| ចំនួនបុគ្គលិក | ២.២៥៣ | ៣.០៦៧ | ២.៩៨៤ | ៣.៥២៩ |
| ចំនួនទីតាំងម៉ាស៊ីន ATM | ២៣៩ | ៣៦០ | ៣៥៨ | ៣៩១ |
| **ធនាគារសាខាបរទេស** | | | | |
| ចំនួនធនាគារ | ៩ | ១០ | ១១ | ១០ |
| ចំនួនសាខា | ១៣ | ១៦ | ២១ | ២២ |
| ចំនួនបុគ្គលិក | ២៨៨ | ៣៦១ | ៤៣៩ | ៤៦៣ |
| ចំនួនទីតាំងម៉ាស៊ីន ATM | ២ | ២ | ៦ | ៨ |
| **ចំនួនសរុបធនាគារពាណិជ្ជ** | | | | |
| ចំនួនធនាគារសរុប | ៣២ | ៣៥ | ៣៦ | ៣៦ |
| ចំនួនសាខាសរុប | ៤៤៨ | ៤៨៧ | ៥៤១ | ៥៩៣ |
| ចំនួនបុគ្គលិកសរុប | ១៣.២២៣ | ១៦.២២១ | ១៩.៧៦៣ | ២១.៩៦៩ |
| ចំនួនទីតាំងម៉ាស៊ីន ATM សរុប | ៦៨១ | ៧៦៦ | ៩៤០ | ១.១១៨ |
| **ធនាគារឯកទេស** | | | | |
| **ធនាគារឯកទេសរបស់រដ្ឋ** | | | | |
| ចំនួនធនាគារ | ១ | ១ | ១ | ១ |
| ចំនួនសាខា | ១ | ១ | ១ | ១ |
| ចំនួនបុគ្គលិក | ៦០ | ៥៩ | ៦៧ | ៧៥ |
| **ធនាគារឯកទេស– ភាគទុនិកភាគច្រើនជាអ្នកក្នុងស្រុក** | | | | |
| ចំនួនធនាគារ | ៣ | ៤ | ៤ | ៣ |
| ចំនួនសាខា | ៣ | ៦ | ៧ | ៧ |
| ចំនួនបុគ្គលិក | ១៣៨ | ២៤៣ | ១៧៨ | ៤០៧ |
| **ធនាគារឯកទេស– ភាគទុនិកភាគច្រើនជាជនបរទេស** | | | | |
| ចំនួនធនាគារ* | ៣ | ៣ | ៦ | ៧ |
| ចំនួនសាខា | ៣ | ៣ | ៨ | ១៣ |
| ចំនួនបុគ្គលិក | ៤៦ | ៩៥ | ២៦៥ | ៣៨១ |

[1] តួលេខទាំងនេះបានមកពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលមាននៅក្នុងឧបសម្ព័ន្ធទី២

| | | | | |
|---|---|---|---|---|
| **ចំនួនសរុបធនាគារឯកទេស** | | | | |
| ចំនួនធនាគារសរុប | ៧ | ៨ | ១១ | ១១ |
| ចំនួនសាខាសរុប | ៧ | ១០ | ១៦ | ២១ |
| ចំនួនបុគ្គលិកសរុប | ២៤៥ | ៣៩៧ | ៥១០ | ៨៦៣ |
| **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ** | | | | |
| **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ** | | | | |
| ចំនួនគ្រឹះស្ថាន | ៧ | ៧ | ៧ | ៨ |
| ចំនួនសាខា | ១.៤២៤ | ១.២៧៩ | ១.៣៨៣ | ១.៦៣២ |
| ចំនួនបុគ្គលិក | ១០.៤០៣ | ១២.៨៤២ | ១៥.៥៧៦ | ២០.៨០៨ |
| ចំនួនទីតាំងម៉ាស៊ីន ATM | ៣១ | ៧៣ | ១៩៧ | ២៩៨ |
| **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ** | | | | |
| ចំនួនគ្រឹះស្ថាន | ២៨ | ២៩ | ៣២ | ៥០ |
| ចំនួនសាខា | ៧៥២ | ៩៣៧ | ១.៣១១ | ២.១៨៦ |
| ចំនួនបុគ្គលិក | ២.២១៥ | ២.៩៦៤ | ៤.០១៤ | ៥.៤៦០ |
| **ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុដែលបានចុះបញ្ជី** | | | | |
| ចំនួនគ្រឹះស្ថាន | ៣២ | ៣៥ | ៣៨ | ១០៩ |
| ចំនួនសាខា | ២៧៦ | ៤៤៣ | ៥០៩ | ១.៧១៥ |
| ចំនួនបុគ្គលិក | ៥៣៩ | ៨៩៧ | ៩៤២ | ៣.២៥៥ |
| **ចំនួនគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ** | | | | |
| ចំនួនគ្រឹះស្ថានសរុប | ៦៧ | ៧១ | ៧៧ | ១៦៧ |
| ចំនួនសាខាសរុប | ២.៤៥២ | ២.៦៥៩ | ៣.២០៣ | ៥.៥៣៣ |
| ចំនួនបុគ្គលិកសរុប | ១៣.១៥៧ | ១៦.៧០៣ | ២០.៥៣២ | ២៩.៥២៣ |
| ចំនួនទីតាំងម៉ាស៊ីន ATM សរុប | ៣១ | ៧៣ | ១៩៧ | ២៩៨ |
| **ក្រុមហ៊ុនភតិសន្យា** | | | | |
| **ចំនួនក្រុមហ៊ុនភតិសន្យា** | | | | |
| ចំនួនក្រុមហ៊ុនសរុប | ១ | ២ | ៦ | ៩ |
| **ការិយាល័យតំណាង** | | | | |
| **ចំនួនការិយាល័យតំណាងធនាគារបរទេស** | | | | |
| ចំនួនការិយាល័យសរុប | ៤ | ៦ | ៧ | ៨ |

តារាង២: ចំណែកទីផ្សារនៃគ្រឹះស្ថានធនាគារតាមភាគទុនិក

| ចំណែកទីផ្សារ | ទ្រព្យសកម្ម | | ឥណទាន | | ប្រាក់បញ្ញើ | | ដើមទុន | |
|---|---|---|---|---|---|---|---|---|
| | ធ្នូ-១៤ | ធ្នូ-១៥ | ធ្នូ-១៤ | ធ្នូ-១៥ | ធ្នូ-១៤ | ធ្នូ-១៥ | ធ្នូ-១៤ | ធ្នូ-១៥ |
| **ធនាគារពាណិជ្ជ** | | | | | | | | |
| ធនាគារបរទេស | ៥៤,៥៩% | ៥៤,២៩% | ៥០,៤០% | ៥១,៥៨% | ៥២,៧២% | ៥១,៤៤% | ៦២,៦៨% | ៦០,៩៩% |
| ធនាគារក្នុងស្រុក | ៤៤,១១% | ៤៤,២៣% | ៤៧,៨៩% | ៤៦,៧៦% | ៤៧,២៥% | ៤៨,៥៤% | ៣២,១១% | ៣១,៤៤% |
| **ធនាគារឯកទេស** | | | | | | | | |
| ធនាគារបរទេស | ០,៦៤% | ០,៧៤% | ០,៩៤% | ១,០២% | ០,០០% | ០,០០% | ២,៧១% | ៤,០២% |
| ធនាគារក្នុងស្រុក | ០,៦៦% | ០,៧៤% | ០,៧៧% | ០,៦៤% | ០,០៣% | ០,០១% | ២,៥០% | ៣,៥៥% |
| **សរុប** | | | | | | | | |
| ធនាគារបរទេស | ៥៥,២៣% | ៥៥,០៣% | ៥១,៣៥% | ៥២,៦០% | ៥២,៧២% | ៥១,៤៥% | ៦៥,៣៩% | ៦៥,០១% |
| ធនាគារក្នុងស្រុក | ៤៤,៧៧% | ៤៤,៩៧% | ៤៨,៦៥% | ៤៧,៤០% | ៤៧,២៨% | ៤៨,៥៥% | ៣៤,៦១% | ៣៤,៩៩% |
| **សរុប** | **១០០%** | **១០០%** | **១០០%** | **១០០%** | **១០០%** | **១០០%** | **១០០%** | **១០០%** |

## ១.២. ស្ថានភាពនិងប្រតិបត្តិការហិរញ្ញវត្ថុ

### ១.២.១. ប្រតិបត្តិការនៃវិស័យធនាគារ

ប្រព័ន្ធហិរញ្ញវត្ថុនៅកម្ពុជាគ្របដណ្តប់ដោយប្រព័ន្ធធនាគារ ដែលមានទំហំទ្រព្យសកម្មសរុបប្រមាណជាង ៩០% នៃទ្រព្យសកម្មនៃប្រព័ន្ធហិរញ្ញវត្ថុ ។ ក្នុងឆ្នាំ២០១៥ ទ្រព្យសកម្មសរុបបានកើនឡើង ២៣,២១% ដល់ ៨០.៨៤៨,៦៩ ពាន់លានរៀល ដែលស្មើនឹង ១០៧,៨៩% នៃផលិតផលក្នុងស្រុកសរុប ។ ដោយឡែក សំពៀតឥណទាននិងប្រាក់បញ្ញើរបស់អតិថិជនសរុបបានកើនឡើង ២៥,៦៥% ដល់ ៤៧.៥៥៤,៥២ ពាន់លានរៀល និង ១៧,៣៨% ដល់ ៤៦.៣៤៦,០៣ ពាន់លានរៀល ស្មើនឹង ៦៣,៤៦% និង ៦១,៨៥% នៃផលិតផលក្នុងស្រុកសរុប រៀងគ្នា ។ ដើម្បីធានាដល់ភាពរឹងមាំនៃការអភិវឌ្ឍវិស័យនេះ គ្រឹះស្ថានធនាគារបានបង្កើនប្រសិទ្ធភាព និងវិសាលភាពប្រតិបត្តិការរបស់ខ្លួនតាមរយៈការបើកសាខាធនាគារថ្មីចំនួន ៥៧ និង POS ចំនួន ៣.៨០៨ និងការដាក់ឲ្យដំណើរការម៉ាស៊ីនអេធីអឹម (ATM) ថ្មីចំនួន ១៧៨ ម៉ាស៊ីន ព្រមទាំងការចេញឲ្យប្រើប្រាស់នូវប័ណ្ណឥណពន្ធចំនួន ១៤៣.០១២ និងប័ណ្ណឥណទានចំនួន ៨.៥៧៥ ។

តារាង៣: ការវិវត្តក្នុងវិស័យធនាគារ (កំណើនឆ្នាំលើឆ្នាំ)

| ការវិវត្តក្នុងវិស័យធនាគារ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|---|---|
| កំណើនទ្រព្យសកម្ម | ២៤,៤០% | ៣៧,៣០% | ១៦,៩០% | ២៧,១០% | ២៣,២១% |
| កំណើនឥណទាន | ៣៣,៥០% | ៣៥,១០% | ២៥,៧៦% | ២៧,១១% | ២៥,៦៥% |
| កំណើនប្រាក់បញ្ញើ | ២០,៤០% | ២៩,៧០% | ១២,២៤% | ២៨,៩៥% | ១៧,៣៨% |
| ទ្រព្យសកម្មធៀបផ.ស.ស | ៦២,៧០% | ៧៦,៦០% | ៨២,៧៨% | ៩៨,៣៣% | ១០៧,៨៩% |
| ឥណទានធៀបផ.ស.ស | ៣៤,១០% | ៤១,០០% | ៤៧,៧៤% | ៥៦,៧១% | ៦៣,៤៦% |
| ប្រាក់បញ្ញើធៀបផ.ស.ស | ៤១,០០% | ៤៧,៣០% | ៤៩,០៩% | ៥៩,១៦% | ៦១,៨៥% |

រូបភាព២: ធនាគារ-ចំនួនអ្នកខ្ចីប្រាក់និងអ្នកដាក់ប្រាក់បញ្ញើ




រូបភាព៣: ធនាគារ-ឥណទាននិងប្រាក់បញ្ញើទៅអតិថិជន



រូបភាព៤: ធនាគារ–ឥណទានតាមវិស័យសេដ្ឋកិច្ច




រូបភាព៥: ធនាគារ–អនុបាតឥណទានមិនដំណើរការ




សុខមាលភាព និងភាពរឹងមាំនៃប្រព័ន្ធធនាគារគួបផ្សំនឹងការកើនឡើងនៃការយល់ដឹងរបស់ប្រជាជនលើវិស័យហិរញ្ញវត្ថុ ការពង្រីកបណ្តាញប្រតិបត្តិការអន្តរការិយហិរញ្ញវត្ថុ ក៏ដូចជាការកើនឡើងនៃជម្រើសផលិតផលនិងសេវាហិរញ្ញវត្ថុ បានជំរុញនិងបង្កើនការប្រើប្រាស់សេវាហិរញ្ញវត្ថុតាមរយៈប្រព័ន្ធធនាគារកាន់តែច្រើនជាងមុន ។ ក្នុងឆ្នាំ២០១៥ នេះ អ្នកដាក់ប្រាក់បញ្ញើកើនឡើង ១៧,៣៨% ពី ២.២៥៩.៦០១ នាក់ ដល់ ២.៦៥០.១៨៨ នាក់ និងអ្នកខ្ចីប្រាក់កើនឡើង ១៥,៥៨% ពី ៤៤៣.៤៨២ នាក់ ដល់ ៥១២.៥៨២នាក់ ។

ទន្ទឹមនឹងការកើនឡើងនូវចំនួនអតិថិជនក្នុងវិស័យធនាគារ ប្រាក់បញ្ញើនិងឥណទានក៏មានការកើនឡើងផងដែរ ។ ជាក់ស្តែង តាមរយៈផលធៀបឆ្នាំលើឆ្នាំ ប្រាក់បញ្ញើនិងឥណទានបានកើនឡើង ១៧,៣៨% និង ២៥,៦៥% រៀងគ្នា ។ ទោះបីជាកំណើនឥណទាននៅក្នុងឆ្នាំ២០១៥ នេះ មានកម្រិតខ្ពស់ក្តី ក៏នៅទាបជាងកំណើនឆ្នាំ២០១៤ និងមាននិន្នាការថយចុះជាបន្តបន្ទាប់ ។ កត្តានេះ បានឆ្លុះបញ្ចាំងពីផលវិជ្ជមាននៃការប្រែប្រួលនិន្នាការនៃការផ្តល់ឥណទានរបស់គ្រឹះស្ថានធនាគារ ដោយគ្រឹះស្ថានមានការយកចិត្តទុកដាក់ខ្ពស់ និងបង្កើនការប្រុងប្រយ័ត្នជាងមុនក្នុងការបញ្ចេញឥណទានទៅលើវិស័យដែលអាចប្រឈមនឹងហានិភ័យ ព្រមទាំងពង្រឹងគុណភាព និងនិរន្តរភាពនៃដើមទុនរបស់គ្រឹះស្ថានផងដែរ ។ គួរបញ្ជាក់ផងដែរថា កំណើនឥណទាននៅកម្ពុជាត្រូវបានបែងចែកទៅតាមវិស័យសេដ្ឋកិច្ចរួមមាន៖ វិស័យពាណិជ្ជកម្មលក់ដុំ ១៧,០១% ពាណិជ្ជកម្មលក់រាយ ១៥,៧៣% កសិកម្មរុក្ខាប្រមាញ់និងនេសាទ ១០,១៩% និងសេវាផ្សេងៗមិនមែនហិរញ្ញវត្ថុ ៨,៣៧% នៃសំពៀតឥណទានសរុប ។ ចំណែកវិស័យផ្សេងទៀតក្រៅពីវិស័យខាងលើ បានស្រូបយកឥណទានតិចជាង ៨% នៃសំពៀតឥណទានសរុប ។ ឥណទានមិនដំណើរការដុលធៀបនឹងឥណទានសរុបមានមានលក្ខណៈប្រសើរជាងឆ្នាំ២០១៤ ដោយបានរក្សានូវកម្រិតទាបត្រឹមតែ ១,៩៩% ដែលនេះបានបង្ហាញពីប្រសិទ្ធភាពនៃការគ្រប់គ្រងគុណភាពទ្រព្យសកម្ម ជាពិសេសការបញ្ចេញឥណទានរបស់គ្រឹះស្ថានធនាគារ ។

គ្រឹះស្ថានធនាគារបានរក្សាអនុបាតសន្ទនីយភាពស្ថិតនៅកម្រិតល្អប្រសើរដូចឆ្នាំមុនជាមួយនឹងអត្រា ៧៨,៧៨% ខ្ពស់ជាងកម្រិតកំណត់ ៥០% ហើយការគ្រប់គ្រងសន្ទនីយភាពនឹងរំពឹងមានប្រសិទ្ធភាពកាន់តែប្រសើរជាងមុន បន្ទាប់ពីការដាក់

ឲ្យអនុវត្តនូវប្រកាសស្តីពីអនុបាតក្របខ័ណ្ឌសន្ទនីយភាពដែលស្របតាមបាសែល ៣ នាចុងឆ្នាំ២០១៥ នេះ ។ ជាមួយគ្នាផងដែរ ដើម្បីធានាបាននូវភាពគ្រប់គ្រាន់នៃដើមទុន គ្រឹះស្ថានធនាគារបានបន្ថែមដើមទុនជាលំដាប់ ដែលភាគច្រើនបានមកពីប្រាក់ចំណេញបង្គរទុករបស់គ្រឹះស្ថាន ។ ជាក់ស្តែង គ្រឹះស្ថានធនាគារបានរក្សាអនុបាតសាធនភាពរបស់ខ្លួនយ៉ាងរឹងមាំជាមួយនឹងកម្រិតជាមធ្យមប្រមាណ ២១,៨៦% លើសពីកម្រិតកំណត់អប្បបរមានៃបទប្បញ្ញត្តិ ១៥% ។ ទន្ទឹមនឹងការពង្រឹងការអនុវត្តនិងការបង្កើនប្រសិទ្ធភាពការងារ ចំណូលការប្រាក់សុទ្ធរបស់គ្រឹះស្ថានបានកើនឡើង ២៨,៥៤% ហើយផលរបរលើទ្រព្យសកម្ម និងផលរបរលើដើមទុនមានកម្រិត ១,៩៦% និង ១០,៩២% រៀងគ្នា ។

## ១.២.២. ប្រតិបត្តិការនៃវិស័យមីក្រូហិរញ្ញវត្ថុ

ចាប់ពីឆ្នាំ២០១០ រហូតដល់បច្ចុប្បន្ន ប្រតិបត្តិការមីក្រូហិរញ្ញវត្ថុនៅកម្ពុជាមានការរីកចម្រើនជាលំដាប់គួរឲ្យកត់សម្គាល់។ ការរីកចម្រើននៃវិស័យនេះ បានឆ្លុះបញ្ចាំងតាមរយៈកំណើននៃចំនួនគ្រឹះស្ថានថ្មី កំណើនទ្រព្យសកម្ម ឥណទានអតិថិជនប្រាក់បញ្ញើអតិថិជន បណ្តាញប្រតិបត្តិការហិរញ្ញវត្ថុ និងផលិតផលនិងសេវាហិរញ្ញវត្ថុថ្មីៗ ។ វិស័យមីក្រូហិរញ្ញវត្ថុបានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ប្រភពទុនដល់ប្រជាពលរដ្ឋនៅតាមទីជនបទឲ្យមានលទ្ធភាពបង្កើតមុខរបរថ្មី និងពង្រីកអាជីវកម្មខ្នាតតូចនិងខ្នាតមធ្យម ដែលកត្តានេះចូលរួមចំណែកយ៉ាងសកម្មក្នុងការទ្រទ្រង់ជីវភាពប្រជាពលរដ្ឋ កាត់បន្ថយភាពក្រីក្រ និងជាពិសេសការអភិវឌ្ឍសេដ្ឋកិច្ច ។

នៅឆ្នាំ២០១៥ នេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានចំនួន ៥៨ ក្នុងនោះ មានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន ៨ ។ ការកើនឡើងនៃចំនួនគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានជំរុញឲ្យមានការកើនឡើងនូវទ្រព្យសកម្មសរុប ៤៨,០១% ដល់ ១៤.៦២៥,៩២ ពាន់លានរៀល ឥណទាន ៤៩,៨៩% ដល់ ១២.២៤៤,៣៦ ពាន់លានរៀល និងប្រាក់បញ្ញើ ៤៧,៣១% ដល់ ៥.៣០០,៨៧ ពាន់លានរៀល ។ ទ្រព្យសកម្មនិងឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុស្មើនឹង ១៩,៥២% និង ១៦,១៩% នៃផលិតផលក្នុងស្រុកសរុប ហើយសំពៀតឥណទាននេះ ត្រូវបានផ្តល់ទៅវិស័យកសិកម្ម ៣៥,២៤% ក្រុមគ្រួសារ ២៦,២២% ការជួញដូរនិងពាណិជ្ជកម្ម ១៩,៣៥% សេវាកម្ម ១០,៦៦% សំណង់និងដឹកជញ្ជូន ៧,១៧% និងផ្សេងៗ ១,៣៦% ។ ការកើនឡើងយ៉ាងឆាប់រហ័សនៃឥណទានក្នុងវិស័យមីក្រូហិរញ្ញវត្ថុនាំមកនូវកំណើនអ្នកខ្ចីឥណទាន ១៤,៨០% ពី ១.៧៧៤.៨១៥ នាក់ ដល់ ២.០៣៧.៤២៤ នាក់ ហើយទំហំឥណទានជាមធ្យមក្នុងវិស័យមីក្រូហិរញ្ញវត្ថុសម្រាប់អតិថិជនម្នាក់ៗ បានកើនឡើងពី ៤,៦៣ លានរៀល ដល់ ៦,០១ លានរៀល បើធៀបទៅនឹងឆ្នាំ២០១៤ ។ ការកើនឡើងនៃទំហំឥណទានមធ្យមនេះ ឆ្លុះបញ្ចាំងអំពីតម្រូវការក៏ដូចជាលទ្ធភាពទទួលបានឥណទានកាន់តែធំឡើងរបស់ប្រជាជននៅតាមជនបទ ដែលសបញ្ជាក់ពីការរីកចម្រើននៃស្ថានភាពសេដ្ឋកិច្ចជនបទ និងជីវភាពរស់នៅរបស់ប្រជាជន ព្រោះថាមុននឹងទទួលបានឥណទានពីវិស័យមីក្រូហិរញ្ញវត្ថុផ្លូវការ អតិថិជនត្រូវបង្ហាញពីគម្រោងអាជីវកម្មរបស់ខ្លួនឲ្យបានច្បាស់លាស់ និងលទ្ធភាពសងមកវិញនូវប្រាក់កម្ចីទាំងនេះ ។ ឥណទានមិនដំណើរការមានកម្រិតទាបប្រមាណ ០,៧៧% ។ ក្រៅពីនេះ ជំនឿទុកចិត្ត និងការយល់ដឹងប្រសើរជាងមុនរបស់សាធារណជនចំពោះស្ថានភាពសេដ្ឋកិច្ចនិងវិស័យមីក្រូហិរញ្ញវត្ថុ បានជំរុញឲ្យប្រាក់បញ្ញើរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានការកើនឡើងគួរឲ្យកត់សម្គាល់ស្មើនឹង ៧,០៧% នៃផលិតផលក្នុងស្រុកសរុប ។

ទន្ទឹមនឹងការរីកចម្រើននេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានគោរពតាមបទប្បញ្ញត្តិប្រុងប្រយ័ត្ន ដោយបានរក្សានូវអនុបាតសាធនភាព និងសន្ទនីយភាពក្នុងកម្រិតប្រមាណ ១៩,២៦% និង ១៣៨,៤៦% ខ្ពស់ជាងកម្រិតអប្បបរមា ១៥% និង ១០០% ដែលបានកំណត់ដោយបទប្បញ្ញត្តិ ។ ការគ្រប់គ្រងគុណភាពទ្រព្យសកម្មហាក់មានការធ្លាក់ចុះបន្តិច ស្តែងចេញតាមរយៈការកើនឡើងនូវអនុបាតឥណទានមិនដំណើរការពី ០,៥៩% នៅក្នុងឆ្នាំមុន ដល់ ០,៧៧% នៅក្នុងឆ្នាំនេះ ។ បើទោះជាយ៉ាងនេះក៏ដោយ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅតែមានលទ្ធភាពស្វែងរកប្រាក់ចំណេញ ដោយផលរបរលើទ្រព្យសកម្មនិងផលរបរលើដើមទុនមានកម្រិត ៣,៨៦% និង ១៨,៧៦% ដែលមានកម្រិតប្រហាក់ប្រហែលគ្នានឹងឆ្នាំមុន ។

បច្ចុប្បន្ន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានបណ្តាញសាខាចំនួន ៣.៨១៨ បុគ្គលិកចំនួន ២៦.២៦៨ នាក់ និង ATM ចំនួន ២៩៨ ដែលបម្រើដល់អតិថិជនខ្ចីប្រាក់ចំនួន ២.០៣៧.៤២៤ នាក់ និងអតិថិជនដាក់ប្រាក់បញ្ញើចំនួន ១.៣៣៩.៨៩៦ នាក់ នៅទូទាំង ២៥ ខេត្ត-ក្រុងពាសពេញផ្ទៃប្រទេស ។

រូបភាព៦: មីក្រូហិរញ្ញវត្ថុ-កំណើនទ្រព្យសកម្ម




រូបភាព៧: មីក្រូហិរញ្ញវត្ថុ-ឥណទានតាមវិស័យសេដ្ឋកិច្ច




រូបភាព៨: មីក្រូហិរញ្ញវត្ថុ- ឥណទាននិងប្រាក់បញ្ញើ




រូបភាព៩: មីក្រូហិរញ្ញវត្ថុ - គុណភាពសំពៀតឥណទាន



### ១.២.៣. ប្រតិបត្តិការនៃវិស័យភតិសន្យាហិរញ្ញវត្ថុ

បន្ទាប់ពីការឈានចូលរបស់ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុចាប់ពីឆ្នាំ២០១២មក ប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុបានរីកចម្រើនលូតលាស់គួរឲ្យកត់សម្គាល់ ។ គិតមកដល់បច្ចុប្បន្ន ដោយផ្អែកលើច្បាប់ស្ដីពីភតិសន្យាហិរញ្ញវត្ថុ និងប្រកាសទាក់ទងនឹងអាជីវកម្មភតិសន្យាហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា បានផ្ដល់អាជ្ញាប័ណ្ណចំនួន ៩ ដល់ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ។ ប្រតិបត្តិការនេះបានចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការផ្ដល់ហិរញ្ញប្បទានដល់សហគ្រាសខ្នាតតូចបំផុត តូច និងមធ្យម ក្នុងការពង្រឹងនិងពង្រីកប្រតិបត្តិការអាជីវកម្ម ក៏ដូចជាបង្កើតការងារ និងផ្ដល់ប្រាក់ចំណូលដល់ប្រជាពលរដ្ឋដែលរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ។

វិស័យភតិសន្យាហិរញ្ញវត្ថុមានការអភិវឌ្ឍយ៉ាងខ្លាំង ដែលស្តែងឲ្យឃើញតាមរយៈការកើនឡើងច្រើនជាង ២ ដងនៃទ្រព្យសកម្ម និងឥណទានពី ១៨៦,៣៣ ពាន់លានរៀល និង ១៤៧,០៦ ពាន់លានរៀល កាលពីឆ្នាំមុន ដល់ ៤១០,៣៥ ពាន់លានរៀល និង ៣៤៤,៩៧ ពាន់លានរៀល ក្នុងឆ្នាំ២០១៥ ។ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ បានផ្ដល់សេវាភតិសន្យាហិរញ្ញវត្ថុដល់វិស័យជាច្រើនដូចជា ៖ កសិកម្ម ក្រុមគ្រួសារ ពាណិជ្ជកម្ម សំណង់ សេវាកម្ម និងការដឹកជញ្ជូន តាមរយៈទីស្នាក់ការកណ្ដាល និងសាខាចំនួន ១៧ ជាមួយនឹងបុគ្គលិកចំនួន ៨៥៧ នាក់ ដែលបំរើការដល់អតិថិជនចំនួន ៤៣.៤១៣ នាក់ ។

តារាង៩: វិស័យភតិសន្យាហិរញ្ញវត្ថុ (គិតជាពាន់លានរៀល)

| ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|---|
| ចំនួនទ្រព្យសកម្មសរុប | ១៣,៩២ | ៣៧,៤៤ | ១៨៦,៣៣ | ៤១០,៣៥ |
| ចំនួនឥណទានសរុប | ០,៥៩ | ១៦,៤០ | ១៤៧,០៦ | ៣៤៤,៩៧ |
| ឥណទានមិនដំណើរការ | ០% | ០% | ៣,១៦% | ៥,៣១% |
| មូលនិធិផ្ទាល់សុទ្ធ | (១,២២) | ៧,៨៩ | ៣៤,៣៦ | ៤៤,០៤ |
| ចំនួនបុគ្គលិក (នាក់) | ៧៤ | ២១២ | ៥៤៥ | ៨៥៧ |
| ចំនួនអតិថិជន (នាក់) | ១២២ | ២.៦៣៨ | ១៨.៦៨៣ | ៤៣.៤១៣ |

# ២. ការវិវឌ្ឍក្របខណ្ឌនៃការត្រួតពិនិត្យ និងបទប្បញ្ញត្តិ

## ២.១. ការពិនិត្យឡើងវិញ និងការដាក់ចេញនូវបទប្បញ្ញត្តិ

ប្រព័ន្ធធនាគារបាននិងកំពុងរីកចម្រើនយ៉ាងឆាប់រហ័ស ដែលទាមទារឲ្យមានការពង្រឹងក្របខ័ណ្ឌបទប្បញ្ញត្តិជាប្រចាំដើម្បីឆ្លើយតបតាមការវិវឌ្ឍនៃទីផ្សារ និងឧត្តមានុវត្តភាពជាអន្តរជាតិ និងជាពិសេសដើម្បីទប់ទល់និងការពារហានិភ័យសក្ដានុពលនានា ។ លទ្ធផលនៃមេរៀនពីវិបត្តិហិរញ្ញវត្ថុសកលឆ្នាំ២០០៨ បានតម្រូវឲ្យប្រព័ន្ធធនាគារទាំងមូលយកចិត្តទុកដាក់បន្ថែមលើលក្ខខណ្ឌទីផ្សារ ជាពិសេសការគ្រប់គ្រងសន្ទនីយភាព ។ ស្ថិតក្នុងបរិការណ៍នេះ ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យ បានដាក់ចេញនូវវិធានសមស្របមួយចំនួន ក្នុងទិសដៅពង្រឹងសន្ទនីយភាពប្រព័ន្ធធនាគារ ក៏ដូចជាពង្រឹងក្របខ័ណ្ឌនៃការការពារនិងដោះស្រាយវិបត្តិ ដោយក្នុងនោះវិធានសំខាន់ ៤ ត្រូវបានដាក់ឲ្យអនុវត្តក្នុងឆ្នាំ២០១៥ រួមមាន ៖

១. សេចក្តីជូនដំណឹងលេខ ធ៧-០១៥-១៧៧ ស.ជ.ណ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៥ ស្តីពី "ការអនុវត្តការដាក់ប្រាក់បម្រុងកាតព្វកិច្ចលើ (១) ប្រាក់បញ្ញើអតិថិជន (២) ប្រាក់បញ្ញើធនាគារអនិវាសជន និង (៣) ប្រាក់កម្ចីអនិវាសជន"

២. ប្រកាសលេខ ធ៧-០១៥-១៥៣ ប្រ.ក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥ ស្តីពី "ការផ្តល់សន្ទនីយភាពចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ"

៣. ប្រកាសលេខ ធ៧-០១៥-១៥៤ ប្រ.ក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥ ស្តីពី "ការចែករំលែកព័ត៌មានត្រួតពិនិត្យរវាងអាជ្ញាធរត្រួតពិនិត្យ និងបញ្ញត្តិករក្នុងនិងក្រៅប្រទេស" និង

៤. ប្រកាសលេខ ធ៧-០១៥-៣៤៩ ប្រ.ក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពី "អនុបាតគ្របដណ្តប់សន្ទនីយភាព" អនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលទទួលប្រាក់បញ្ញើពីសាធារណជន ។

### ២.១.១.ការតម្កល់ប្រាក់បម្រុងកាតព្វកិច្ច និងវិធានម៉ាក្រូប្រុងប្រយ័ត្នផ្សេងៗ

ប្រាក់បម្រុងកាតព្វកិច្ចបានដើរតួនាទីសំខាន់សម្រាប់បម្រើឲ្យគោលនយោបាយរូបិយវត្ថុរបស់ធនាគារកណ្តាល និងជាឧបករណ៍ម៉ាក្រូប្រុងប្រយ័ត្នរបស់អាជ្ញាធរត្រួតពិនិត្យ ។ ក្នុងទិសដៅពង្រឹងស្ថានភាពសន្ទនីយភាពប្រព័ន្ធធនាគារឲ្យមានកម្រិតខ្ពស់និងប្រសើរជាងមុន ក៏ដូចជាដើម្បីទប់ស្កាត់ហានិភ័យបណ្តាលមកពីកំណើនឥណទានយ៉ាងឆាប់រហ័ស និងការប្រែប្រួលនៃប្រភពទុនបរទេស (Foreign Funding Volatility) ក្នុងខែមីនា ឆ្នាំ២០១៥ ធនាគារជាតិនៃកម្ពុជាបានចេញសេចក្តីជូនដំណឹងដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឲ្យគណនាប្រាក់បម្រុងកាតព្វកិច្ចផ្អែកលើ (១) ប្រាក់បញ្ញើអតិថិជន (២) ប្រាក់បញ្ញើធនាគារអនិវាសជន និង (៣) ប្រាក់កម្ចីអនិវាសជន ។

ការពង្រឹងការអនុវត្តនេះ នឹងរួមចំណែករក្សាស្ថិរភាពហិរញ្ញវត្ថុ និងគាំទ្រកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ។ យ៉ាងណាមិញ ឧបករណ៍ត្រួតពិនិត្យម៉ាក្រូប្រុងប្រយ័ត្នដែលធនាគារជាតិនៃកម្ពុជាបាននិងកំពុងប្រើប្រាស់បច្ចុប្បន្ន មិនទាន់មានភាពទូលំទូលាយនៅឡើយទេ ក៏ប៉ុន្តែ ដើម្បីឆ្លើយតបនឹងការវិវឌ្ឍនៃវិស័យធនាគារក្នុងពេលអនាគតដ៏ខ្លី ជាពិសេសដើម្បីទប់ស្កាត់ហានិភ័យឥណទាន វិធានមួយចំនួនកំពុងត្រូវបានពិចារណា ។

### ២.១.២. ការផ្តល់សន្ទនីយភាពបន្ទាន់ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ក្នុងគោលដៅទប់ស្កាត់ហានិភ័យជាប្រព័ន្ធ និងរក្សាស្ថិរភាពហិរញ្ញវត្ថុ កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥ ធនាគារជាតិនៃកម្ពុជា បានធ្វើការកែសម្រួលនិងដាក់ឲ្យអនុវត្តនូវប្រកាសថ្មីស្តីពី "ការផ្តល់សន្ទនីយភាព ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ" ដែលទទួលប្រាក់បញ្ញើពីសាធារណជន ជំនួសឲ្យប្រកាសចាស់ស្តីពី "ការផ្តល់ឥណទានវិបារូបន៍ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលខ្វះសាច់ប្រាក់ងាយស្រួលបណ្តោះអាសន្ន" ដែលអនុវត្តកន្លងមក ។ បទប្បញ្ញត្តិថ្មីនេះ មានសារៈសំខាន់ក្នុងការពង្រឹងតួនាទីរបស់ធនាគារជាតិនៃកម្ពុជា ជាអ្នកឲ្យខ្ចីចុងក្រោយ (Lender of Last Resort) ដោយបម្រើឲ្យយន្តការដោះស្រាយតម្រូវការសន្ទនីយភាពចាំបាច់របស់គ្រឹះស្ថានស្ថិតក្រោមអាណាព្យាបាល ។ គ្រឹះស្ថានដែលជួបបញ្ហាកង្វះសន្ទនីយភាពបន្ទាន់ ត្រូវចាត់ទុកការផ្តល់សន្ទនីយភាពនេះជាមធ្យោបាយចុងក្រោយ ហើយដើម្បីទទួលបាន គ្រឹះស្ថានត្រូវមានសាធនភាព ចំណេញ និងអនុវត្តបានពេញលេញតាមបទប្បញ្ញត្តិប្រុងប្រយ័ត្ន ព្រមទាំងមានវត្ថុធានាដែលអាចទទួលយកបានដោយធនាគារជាតិនៃកម្ពុជា ។

### ២.១.៣. ការចែករំលែកព័ត៌មានត្រួតពិនិត្យរវាងអាជ្ញាធរត្រួតពិនិត្យ

ធនាគារជាតិនៃកម្ពុជាក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យ បានបង្កើតនិងពង្រីកកិច្ចសហប្រតិបត្តិការជាបន្តបន្ទាប់ជាមួយអាជ្ញាធរពាក់ព័ន្ធក្នុង និងក្រៅប្រទេស ក្នុងគោលបំណងពង្រឹងប្រសិទ្ធភាពនៃការត្រួតពិនិត្យ និងរៀបចំយន្តការការពារ និងដោះស្រាយវិបត្តិដែលចាំបាច់នានា ។ កន្លងមក ធនាគារជាតិនៃកម្ពុជា បានចុះអនុស្សារណៈនៃការយោគយល់ក្នុងក្របខ័ណ្ឌនៃការចែករំលែកព័ត៌មាន ជាមួយអាជ្ញាធរត្រួតពិនិត្យមួយចំនួនក្នុងតំបន់ និងអន្តរជាតិ ទាំងក្នុងកម្រិតទ្វេភាគីនិងពហុភាគី ។ ដើម្បីគាំទ្រដល់ការអនុវត្តកិច្ចសហប្រតិបត្តិការទាំងនេះ កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥ ធនាគារជាតិនៃកម្ពុជា បានដាក់ចេញនូវប្រកាសស្តីពី "ការចែករំលែកព័ត៌មានត្រួតពិនិត្យរវាងអាជ្ញាធរត្រួតពិនិត្យ និងបញ្ញត្តិករក្នុងនិងក្រៅប្រទេស" ដោយកំណត់ក្របខ័ណ្ឌនៃការចែករំលែកព័ត៌មានត្រួតពិនិត្យ ទៅតាមទម្រង់ដូចខាងក្រោម ៖

(១) កិច្ចប្រជុំទ្វេភាគីរវាងអាជ្ញាធរត្រួតពិនិត្យ និងបញ្ញត្តិករទាំងក្នុងនិងក្រៅប្រទេស

(២) អនុស្សារណៈយោគយល់គ្នារវាងអាជ្ញាធរត្រួតពិនិត្យ និងបញ្ញត្តិករទាំងក្នុងនិងក្រៅប្រទេស

(៣) កិច្ចប្រជុំរវាងមន្ត្រីត្រួតពិនិត្យ និងបញ្ញត្តិករទាំងក្នុងនិងក្រៅប្រទេស និង

(៤) កិច្ចទំនាក់ទំនងផ្សេងទៀតតាមការចាំបាច់ ។

### ២.១.៤.ការធ្វើបច្ចុប្បន្នកម្មបទប្បញ្ញត្តិសន្ទនីយភាព(LCR)

គណៈកម្មាធិការបាសែល បានឯកភាពលើកំណែទម្រង់មួយ ក្រោយវិបត្តិហិរញ្ញវត្ថុសកលឆ្នាំ២០០៨ ដើម្បីធ្វើឲ្យវិស័យធនាគារកាន់តែរឹងមាំដែលអាចទប់ទល់នឹងហានិភ័យ ។ ហេតុនេះ ឆ្នាំ២០១៣ គណៈកម្មាធិការបាសែល បានចេញផ្សាយឯកសារមួយស្តីពីអនុបាតសន្ទនីយភាព (Liquidity coverage ratio) ក្នុងគោលបំណងលើកកម្ពស់ភាពធន់ទៅនឹងហានិភ័យសន្ទនីយភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។ ប្រទេសជាច្រើនលើពិភពលោក រួមទាំងប្រទេសនៅក្នុងតំបន់អាស៊ានផង បាននិងកំពុងធ្វើកំណែទម្រង់ក្របខ័ណ្ឌបទប្បញ្ញត្តិសន្ទនីយភាព ស្របតាមក្របខ័ណ្ឌសន្ទនីយភាពនៃទីក្រុងបាសែល ។ ដោយយល់ឃើញពីភាពខ្វះខាតនៃប្រកាសស្តីពី "អនុបាតសាច់ប្រាក់ងាយស្រួល" និងដើម្បីអនុលោមតាមក្របខ័ណ្ឌបាសែល ៣ កាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ធនាគារជាតិនៃកម្ពុជាបានចេញប្រកាសស្តីពី "ក្របខ័ណ្ឌសន្ទនីយភាព" អនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើពីសាធារណជន ។ ប្រកាសនេះមានគោលដៅសំខាន់ចំនួន ៣ គឺ (១) បង្កើនភាពធន់រយៈពេលខ្លីចំពោះហានិភ័យសន្ទនីយភាពរបស់គ្រឹះស្ថាន (២) ធានាថាគ្រឹះស្ថានមានបរិមាណទ្រព្យសកម្មសន្ទនីយគ្រប់គ្រាន់មិនជាប់កាតព្វកិច្ចដែលអាចបំលែងជាសាច់ប្រាក់ដោយមិនខាតបង់ ឬខាតបង់តិចតួចពីតម្លៃនៅលើទីផ្សារ ដើម្បីបំពេញតម្រូវការសន្ទនីយភាពក្នុងស្រ្តេសសេណារីយ៉ូ សម្រាប់រយៈពេល៣០ថ្ងៃ និង (៣) ធានាថានៅពេលដែលអនុបាតសន្ទនីយភាពនេះធ្លាក់ចុះក្រោមកម្រិតកំណត់អប្បបរមា គណៈគ្រប់គ្រងគ្រឹះស្ថានត្រូវចាត់វិធានការកែតម្រូវបន្ទាន់ ។

ដោយមានមូលដ្ឋានផ្អែកលើក្របខ័ណ្ឌបាសែល ៣ ធនាគារជាតិនៃកម្ពុជា បានកែសម្រួលតម្រូវការខ្លះៗនៃអនុបាតនេះ ដើម្បីឆ្លុះបញ្ចាំងពីស្ថានភាព និងការវិវឌ្ឍជាក់ស្តែងនៃវិស័យធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា ។ គ្រឹះស្ថានមានរយៈពេល ៤ ឆ្នាំ ដល់ ថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ ដើម្បីគោរពបាននូវអនុបាតក្របខ័ណ្ឌសន្ទនីយភាពពេញលេញ ១០០% ហើយក្នុងរយៈពេលនេះ គ្រឹះស្ថានត្រូវធ្វើការកែប្រែរចនាសម្ព័ន្ធតារាងតុល្យការ កែលម្អប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យានិងកែប្រែយុទ្ធសាស្រ្តប្រតិបត្តិការមួយចំនួន ។ ការអនុវត្តតាមត្រូវធ្វើឡើងជា ៥ ដំណាក់កាល ដោយគ្រឹះស្ថានត្រូវគោរពឲ្យបាននូវអនុបាតជាអប្បបរមាចំនួន ៦០% ចាប់ផ្តើមពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦ តទៅ ។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើដែល

បង្កើតឡើងនៅក្នុងប្រទេសកម្ពុជា ត្រូវគណនាអនុបាតក្របខ័ណ្ឌសន្ទនីយភាពទាំងកម្រិតគ្រឹះស្ថាន និងកម្រិតគួបសរុប រីឯគ្រឹះស្ថានដែលជាសាខារបស់ធនាគារបរទេសត្រូវគណនាត្រឹមកម្រិតគ្រឹះស្ថានប៉ុណ្ណោះ ។

## ២.២.សកម្មភាពនៃការត្រួតពិនិត្យ

ដើម្បីធានាដល់ប្រសិទ្ធភាពអនុវត្តការងាររបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុប្រកបដោយសុវត្ថិភាព និងភាពរឹងមាំ ក៏ដូចជាពង្រឹងជំនឿទុកចិត្តរបស់សាធារណជនមកលើប្រព័ន្ធធនាគារ ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យបានយកចិត្តទុកដាក់យ៉ាងខ្លាំងលើការគ្រប់គ្រងហានិភ័យរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តាមរយៈការត្រួតពិនិត្យលើឯកសារនិងការត្រួតពិនិត្យដល់ទីកន្លែងជាប់ជាប្រចាំ ។ ការត្រួតពិនិត្យលើឯកសារ ត្រូវបានអនុវត្តជាប្រចាំ ផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំគ្រាដែលផ្តល់ដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុរួមមាន ៖ របាយការណ៍ប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ប្រចាំ ២ សប្តាហ៍ ប្រចាំខែ និងប្រចាំត្រីមាស ខណៈដែលការត្រួតពិនិត្យដល់ទីកន្លែងត្រូវបានអនុវត្តដោយផ្អែកលើផែនការប្រចាំឆ្នាំ និងតាមការចាំបាច់ ។

ប្រសិទ្ធភាពនៃការអនុវត្តការងារ និងការគ្រប់គ្រងហានិភ័យរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវបានវាយតម្លៃផ្អែកលើហានិភ័យយុទ្ធសាស្ត្រ ហានិភ័យឥណទាន ហានិភ័យទីផ្សារ ហានិភ័យប្រតិបត្តិការ និងហានិភ័យសន្ទនីយភាព ព្រមទាំងការធ្វើចំណាត់ថ្នាក់លើធាតុនីមួយៗនៃវិធីសាស្ត្រ CAMELS (ដើមទុន ទ្រព្យសកម្ម ការគ្រប់គ្រង ប្រាក់ចំណេញ សន្ទនីយភាព និងវេទយិតភាព) ។ សកម្មភាពកែតម្រូវសមស្របនឹងត្រូវដាក់ចេញ ដើម្បីកាត់បន្ថយហានិភ័យពាក់ព័ន្ធ និងហានិភ័យជាប្រព័ន្ធ ប្រសិនបើហានិភ័យទាំងនោះត្រូវបានកំណត់អត្តសញ្ញាណ ។

បើទោះជា ការអនុវត្តការងារត្រួតពិនិត្យទទួលបានលទ្ធផលល្អគួរឲ្យកត់សម្គាល់ ចំណុចមួយចំនួនគួរកែលម្អ និងពង្រឹងបន្ថែមដូចជា ៖ ការពិនិត្យការរៀបចំរបាយការណ៍សន្ទនីយភាព ការធ្វើចំណាត់ថ្នាក់ និងសំវិធានធនលើទ្រព្យសកម្ម នីតិវិធីនៃការផ្តល់ឥណទាន អភិបាលកិច្ច និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ។

# ៣.ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងសមាហរណកម្មក្នុងតំបន់

## ៣.១.ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ

### ៣.១.១.ស្តង់ដារគណនេយ្យនិងរបាយការណ៍ហិរញ្ញវត្ថុ

ប្រព័ន្ធគណនេយ្យដែលមានស្តង់ដារនិងគុណភាពខ្ពស់ ដើរតួនាទីសំខាន់ក្នុងការបង្កើនជំនឿទុកចិត្តវិនិយោគិន តាមរយៈការជំរុញសង្គតភាព តម្លាភាព ភាពអាចប្រៀបធៀបបាន និងភាពអាចគួរជឿជាក់បាននៃរបាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាសនីមួយៗ ។ ការអនុវត្តស្តង់ដារគណនេយ្យសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា មានរយៈកាលជាង ១០ ឆ្នាំមកហើយ ដែលចាប់ផ្តើមពីការដាក់ឲ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអនុវត្តនូវប្លង់គណនីឯកភាព ដោយមួយផ្អែកធំផ្អែកលើស្តង់ដារគណនេយ្យកម្ពុជា (CAS) និងស្តង់ដារគណនេយ្យអន្តរជាតិ (IAS) នៅឆ្នាំ២០០២ ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជា បានដាក់ចេញនូវវិធាននិងបទប្បញ្ញត្តិជាបន្តបន្ទាប់ សំដៅពង្រឹងការអនុវត្តស្តង់ដារគណនេយ្យ និងសវនកម្មរបស់គ្រឹះស្ថានស្ថិតក្រោមអាណាព្យាបាល ។ នៅឆ្នាំ២០០៩ ក្រុមប្រឹក្សាជាតិគណនេយ្យ បានប្រកាសដាក់ឲ្យប្រើប្រាស់នូវស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (CIFRS) ដែលអនុលោមទាំងស្រុងតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ (IFRS) សម្រាប់សហគ្រាសដែលមានការទទួលខុសត្រូវជាសាធារណៈ រួមទាំងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផង ។ ក៏ប៉ុន្តែ ដោយប្រឈមនឹងកង្វះខាតមូលនិធិ ធនធានមនុស្ស និងប្រព័ន្ធធនាគារស្នូល គ្រឹះស្ថានមួយចំនួនធំមិន

មានលទ្ធភាពអនុវត្តតាមកាលបរិច្ឆេទដែលបានកំណត់ឡើយ ។ ហេតុដូចនេះ ធនាគារជាតិនៃកម្ពុជា បានតម្រូវឲ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទាំងអស់ សិក្សាលើភាពខ្វះចន្លោះនិងផលប៉ះពាល់នៃការអនុវត្តតាម IFRS ដើម្បីជាមូលដ្ឋានក្នុងការវាយតម្លៃលើភាពរួចរាល់នៃការឈានទៅអនុវត្តពេញលេញតាមស្តង់ដារនេះ ។ ទន្ទឹមនឹងនេះ ការងារចម្បងមួយទៀតដើម្បីសម្រួលដល់ការផ្លាស់ប្តូរទៅអនុវត្តតាម IFRS គឺការបន្ធូរបន្ថយអសង្គតភាពរវាងតម្រូវការរបាយការណ៍ IFRS និងបទប្បញ្ញត្តិប្រុងប្រយ័ត្នមួយចំនួនរបស់ធនាគារជាតិនៃកម្ពុជា ដែលការកែសម្រួលបទប្បញ្ញត្តិទាំងនេះត្រូវធ្វើឡើងស្របតាមការប្រែប្រួលនៃស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិផងដែរ ។ គួរកត់សម្គាល់ថា ទោះបីជាក្រុមប្រឹក្សាគណនេយ្យអន្តរជាតិ (IASB) បានពិនិត្យនិងធ្វើវិសោធនកម្មលើស្តង់ដារ IAS ៣៩ ដោយដាក់ចេញនូវស្តង់ដារ IFRS ៩ ជំនួសវិញ ហើយដែលត្រូវចាប់ផ្តើមអនុវត្តពេញលេញនៅដើមឆ្នាំ២០១៨ ក៏ដោយ ការពិនិត្យនិងពិភាក្សាទៅលើផលវិជ្ជមានឬអវិជ្ជមាននៃស្តង់ដារថ្មីនេះ ទៅលើការគ្រប់គ្រងហានិភ័យឥណទានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅតែបន្ត ។

### ៣.១.២ ការិយាល័យព័ត៌មានឥណទានកម្ពុជា

ក្រុមហ៊ុនក្រេឌីតប៊្យូរ៉ូកម្ពុជា បានចាប់ផ្តើមធ្វើប្រតិបត្តិការនៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១១ ហើយមកដល់បច្ចុប្បន្នក្រុមហ៊ុនបានដំណើរការពេញលេញផ្អែកលើប្រកាសស្តីពីការរាយការណ៍ឥណទានរបស់ធនាគារជាតិនៃកម្ពុជា។ យោងតាមបទប្បញ្ញត្តិគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទាំងអស់ក្នុងប្រទេសកម្ពុជា ត្រូវផ្តល់ទិន្នន័យឲ្យដល់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាននេះហើយជាផ្នែកមួយក្នុងដំណើរការវាយតម្លៃឥណទាន គ្រឹះស្ថានមានកាតព្វកិច្ចទាមទារនូវរបាយការណ៍ឥណទានពីបុគ្គលដែលស្នើសុំប្រាក់កម្ចី ។ ក្រុមហ៊ុនក្រេឌីតប៊្យូរ៉ូកម្ពុជា មានតួនាទីរក្សាទុកនូវទិន្នន័យនិងព័ត៌មានឥណទាន ដែលចូលរួមចំណែកពង្រឹងស្ថិរភាពហិរញ្ញវត្ថុ ជំរុញការផ្តល់ឥណទានប្រកបដោយការទទួលខុសត្រូវរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក៏ដូចជាការពារផលប្រយោជន៍អតិថិជនអ្នកខ្ចីប្រាក់តាមរយៈការផ្តល់នូវទិន្នន័យត្រឹមត្រូវ ច្បាស់លាស់ និងទាន់ពេលវេលា ដល់អតិថិជននិងគ្រឹះស្ថាន ដើម្បីកាត់បន្ថយហានិភ័យឥណទាននិងការពារការឆបោក ឬក្លែងបន្លំផ្សេងៗ ។ បច្ចុប្បន្នក្រុមហ៊ុនក្រេឌីតប៊្យូរ៉ូកម្ពុជាមានសមាជិកសរុបចំនួន ១១៤ ដែលរួមមាន ធនាគារពាណិជ្ជចំនួន ៣៦ ធនាគារឯកទេសចំនួន ១០ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន ៨ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ៤៥ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុចំនួន ៨ និងប្រតិបត្តិករឥណទានចំនួន ៧ និងកំពុងរក្សាទុកនូវរបាយការណ៍ឥណទានរបស់ប្រជាជនកម្ពុជាប្រមាណ ៣ លាននាក់ ។ ក្នុងឆ្នាំ២០១៥ ក្រុមហ៊ុនក្រេឌីតប្យូរ៉ូកម្ពុជាបានសហការជាមួយធនាគារជាតិនៃកម្ពុជា និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ រៀបចំនូវយុទ្ធនាការលើកកម្ពស់ការយល់ដឹងរបស់សាធារណជនចំនួន ២ ដង នៅសាកលវិទ្យាល័យបៀលប្រាយ៍នៅរាជធានីភ្នំពេញ និងសាកលវិទ្យាល័យសៅស៍អ៊ីសថ៍អេសៀ ស្តីពីសារៈសំខាន់នៃការប្រើប្រាស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ។ ក្រុមហ៊ុនក្រេឌីតប្យូរ៉ូកម្ពុជា ក៏គ្រោងនឹងបញ្ចូលផងដែរនូវទិន្នន័យឥណទានរបស់នីតិបុគ្គលទៅក្នុងរបាយការណ៍ឥណទាននៅចុងឆ្នាំ២០១៦ ។

### ៣.១.៣ ប្រតិបត្តិការប្រព័ន្ធទូទាត់

បច្ចុប្បន្ន ប្រព័ន្ធទូទាត់កម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ និងបានរួមចំណែកយ៉ាងសកម្មនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ច តាមរយៈការផ្តល់មធ្យោបាយសម្រាប់សម្រួលដល់ការទូទាត់ក្នុងសកម្មភាពពាណិជ្ជកម្មប្រកបដោយប្រសិទ្ធភាព ។ ដើម្បីរួមចំណែកធ្វើទំនើបកម្មប្រព័ន្ធទូទាត់ ធនាគារជាតិនៃកម្ពុជា បាននិងកំពុងអភិវឌ្ឍប្រព័ន្ធទូទាត់រាយភ្លាមៗ (FAST) ដែលប្រព័ន្ធនេះធ្វើអោយការទូទាត់សងប្រាក់អន្តរធនាគារកាន់តែមានភាពងាយស្រួលឆាប់រហ័ស និងមានសុវត្ថិភាព ព្រោះការទូទាត់តាមរយៈប្រព័ន្ធនេះអាចអោយអតិថិជនទទួលបានមូលនិធិភ្លាមៗ ឆ្លើយតបទៅនឹងតម្រូវការសន្ទនីយភាពបានទាន់ពេលវេលា ។

ទន្ទឹមនោះ ធនាគារជាតិនៃកម្ពុជា ក៏បាននឹងកំពុងអភិវឌ្ឍប្រព័ន្ធ Central Shared Switch ដើម្បីសម្រួលដល់ការធ្វើប្រតិបត្តិការអន្តរធនាគារតាមរយៈប័ណ្ណទូទាត់ (Card) លើម៉ាស៊ីន ATM និងម៉ាស៊ីន POS ។ ប្រព័ន្ធទាំងពីរដែលគ្រោងនឹងដាក់អោយដំណើរការក្នុងអំឡុងឆ្នាំ២០១៦ នេះ នឹងចូលរួមចំណែកលើកកម្ពស់ប្រសិទ្ធភាពក្នុងការទូទាត់និងបរិយាប័ន្នហិរញ្ញវត្ថុ ជំរុញការប្រើប្រាស់ការទូទាត់ជាអេឡិចត្រូនិច កាត់បន្ថយការប្រើប្រាស់សាច់ប្រាក់ក្នុងសេដ្ឋកិច្ច និងផ្តល់លទ្ធភាពអោយប្រទេសកម្ពុជាអាចធ្វើសមាហរណកម្មជាមួយអាស៊ានបានកាន់តែប្រសើរឡើង ។ ក្រៅពីការអភិវឌ្ឍប្រព័ន្ធទូទាត់ ធនាគារជាតិនៃកម្ពុជាក្នុងនាមជាអាជ្ញាធរ ក៏កំពុងរៀបចំបទប្បញ្ញត្តិថ្មីៗបន្ថែមទៀត ដើម្បីពង្រឹងការគ្រប់គ្រងនិងត្រួតពិនិត្យលើប្រតិបត្តិករនិងអ្នកផ្តល់សេវាទូទាត់ដើម្បីឆ្លើយតបទៅនឹងការរីកចម្រើននៃវិស័យទូទាត់ក្នុងទីផ្សារ ។

## ៣.២. ការអនុវត្តការងារបរិយាប័ន្នហិរញ្ញវត្ថុ

ការងារលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ កំពុងត្រូវបានអនុវត្តនិងទទួលបានការយកចិត្តទុកដាក់ខ្ពស់ជាបន្តបន្ទាប់ពីធនាគារជាតិនៃកម្ពុជា ។ ដោយយល់ឃើញពីការកើនឡើងនូវហានិភ័យបណ្តាលមកពីកង្វះខាតការយល់ដឹងផ្នែកហិរញ្ញវត្ថុរបស់សាធារណជន ក៏ដូចជាការកេងចំណេញរបស់ក្រុមជនឆ្លៀតឱកាសមួយចំនួន ធនាគារជាតិនៃកម្ពុជា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានធ្វើសេចក្តីថ្លែងការណ៍រួមជូនសាធារណជនបានជ្រាបនិងដើម្បីទប់ស្កាត់សកម្មភាពផ្តល់ប្រាក់កម្ចីក្រៅផ្លូវការ ក៏ដូចជាការកំណត់ការប្រាក់ខ្ពស់ដែលមានលក្ខណៈកេងប្រវ័ញ្ចរបស់អង្គការមិនមែនរដ្ឋាភិបាល ដែលគ្មានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជា បានរៀបចំយុទ្ធនាការផ្សព្វផ្សាយសេចក្តីថ្លែងការណ៍រួមនេះ ដល់ខេត្តចំនួន ១៤ រួមមាន ៖ កំពង់ចាម ត្បូងឃ្មុំ ព្រៃវែង ស្វាយរៀង កំពង់ស្ពឺ កំពត កែប កំពង់ឆ្នាំង ពោធិ៍សាត់ សៀមរាប បន្ទាយមានជ័យ បាត់ដំបង ប៉ៃលិន និងកណ្តាល ដោយមានការចូលរួមពីមន្ត្រីមកពីក្រសួងមហាផ្ទៃ អាជ្ញាធរដែនដី អង្គការ-សមាគម គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងសាស្ត្រាចារ្យ-និស្សិតសរុបចំនួន ៤.៧៦០ រូប ។ តាមរយៈយុទ្ធនាការផ្សព្វផ្សាយសេចក្តីថ្លែងការណ៍រួមនេះ ធនាគារជាតិនៃកម្ពុជាបានបញ្ជ្រាបនូវការយល់ដឹងរបស់សាធារណជនស្តីពីមុខងារនិងភារៈកិច្ចរបស់ធនាគារជាតិនៃកម្ពុជា សារៈសំខាន់ក្នុងការពង្រឹងនិងជំរុញស្ថិរភាពវិស័យហិរញ្ញវត្ថុ និងការការពារអតិថិជនដែលបានប្រើប្រាស់សេវាហិរញ្ញវត្ថុ ។ បច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជា បាននិងកំពុងចុះត្រួតពិនិត្យដល់ទីកន្លែង និងចេញវិញ្ញាបនប័ត្របញ្ជាក់ការចុះបញ្ជីចំពោះអង្គការមិនមែនរដ្ឋាភិបាល-សមាគម ដែលបានមកដាក់ពាក្យស្នើសុំចុះបញ្ជីជាប្រតិបត្តិករឥណទានជនបទនៅធនាគារជាតិនៃកម្ពុជា ។

សម្រាប់ការងារលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុនេះដែរ ធនាគារជាតិនៃកម្ពុជា បានចូលជាសមាជិកពេញលេញ(Principle Member) របស់សហព័ន្ធបរិយាប័ន្នហិរញ្ញវត្ថុ (AFI) នៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ និងបានចាត់តាំងមន្ត្រីរបស់ខ្លួនចូលរួមក្នុងក្រុមការងារចំនួន ០៦ រួមមាន ៖ ក្រុមការងាររៀបចំយុទ្ធសាស្ត្របរិយាប័ន្នហិរញ្ញវត្ថុ ក្រុមការងារសេវាកម្មហិរញ្ញវត្ថុចល័ត ក្រុមការងារហិរញ្ញវត្ថុសហគ្រាសធុនតូចនិងមធ្យម ក្រុមការងាររៀបចំបទដ្ឋានរួមសម្រាប់បរិយាប័ន្នហិរញ្ញវត្ថុ ក្រុមការងារលើកកម្ពស់សិទ្ធិអតិថិជននិងការអនុវត្តទីផ្សារ និងក្រុមការងារទិន្នន័យបរិយាប័ន្នហិរញ្ញវត្ថុ ។ បន្ថែមពីលើនេះ ធនាគារជាតិនៃកម្ពុជាបានបង្កើតក្រុមការងារបរិយាប័ន្នហិរញ្ញវត្ថុ និងក្រុមការងារកិច្ចការពារអតិថិជន ដើម្បីសហការនិងសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍និងភាគីពាក់ព័ន្ធផ្សេងៗតាមការចាំបាច់ក្នុងការអនុវត្តយុទ្ធសាស្ត្រ និងគម្រោងលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុនៅកម្ពុជាជាពិសេសគឺដើម្បីអនុវត្តគម្រោងចំនួន ៣ ដែលធនាគារជាតិនៃកម្ពុជាបាននិងកំពុងអនុវត្តរួមមាន ៖ ការរៀបចំយុទ្ធសាស្ត្រជាតិសម្រាប់បរិយាប័ន្នហិរញ្ញវត្ថុ ដែលកំពុងអនុវត្តជាមួយ UNCDF កិច្ចការពារអតិថិជនដែលកំពុងអនុវត្តជាមួយ IFC និងការកសាងសមត្ថភាពនិងចំណេះដឹងផ្នែកហិរញ្ញវត្ថុ ដែលកំពុងអនុវត្តជាមួយអង្គការ Good Return របស់ប្រទេសអូស្ត្រាលី ។

រូបភាព១០៖ ចំនួនការិយាល័យ និងម៉ាស៊ីនអេធីអឹមធៀបនឹងប្រជាជន ១០០.០០០ នាក់ (អាយុគិតចាប់ពី ១៥ ឆ្នាំឡើង)




រូបភាព ១១៖ភាគរយអ្នកដាក់ប្រាក់បញ្ញើ និងអ្នកខ្ចីប្រាក់ជាស្ត្រី ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ




ឆ្លងតាមការខិតខំប្រឹងប្រែងលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុក្នុងឆ្នាំកន្លងមក គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានពង្រីកនូវប្រតិបត្តិការរបស់ខ្លួនកាន់តែច្រើន ឆ្លុះបញ្ចាំងតាមរយៈការកើនឡើងនូវបណ្តាញប្រតិបត្តិការ និងចំនួនម៉ាស៊ីនអេធីអឹមរបស់គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅទូទាំងប្រទេស ។ ការណ៍នេះបានបង្កភាពងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការទទួលបានសេវាហិរញ្ញវត្ថុកាន់តែប្រសើរជាងមុនទាំងតម្លៃនិងគុណភាព ។ ជាមួយគ្នានេះដែរ ស្ត្រីនៅតែដើរតួនាទីសំខាន់

ក្នុងការចូលរួមអភិវឌ្ឍន៍វិស័យធនាគារនិងហិរញ្ញវត្ថុ ។ អ្នកដាក់ប្រាក់បញ្ញើនិងអ្នកខ្ចីប្រាក់ជាស្ត្រី នៅតែមានសមាមាត្រខ្ពស់ធៀបទៅនឹងបុរស ។

## ៣.៣. ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន

ដោយសារមានចំណេះដឹងតិចតួចផ្នែកហិរញ្ញវត្ថុ អ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុជាច្រើនអាចងាយរងគ្រោះទៅនឹងការកេងប្រវ័ញ្ចឬក្លែងបន្លំក្នុងរូបភាពផ្សេងៗ ។ បញ្ហានេះគួបផ្សំនឹងភាពស្មុគស្មាញនៃសេវាហិរញ្ញវត្ថុនៅលើទីផ្សារ ការអប់រំផ្នែកហិរញ្ញវត្ថុដើរតួនាទីសំខាន់ក្នុងការផ្តល់លទ្ធភាពឲ្យអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុ ធ្វើការសម្រេចចិត្តត្រឹមត្រូវនិងសមស្របទៅតាមតម្រូវការរបស់ពួកគាត់ ។ ក្នុងន័យនេះ ការអប់រំផ្នែកហិរញ្ញវត្ថុមិនត្រឹមតែណែនាំអ្នកប្រើប្រាស់ឲ្យស្គាល់កាន់តែច្បាស់នូវសេវាហិរញ្ញវត្ថុប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្ហាត់បង្ហាញពួកគាត់ឲ្យចេះគ្រប់គ្រងថវិកា កំណត់ហានិភ័យ និងរៀបចំផែនការហិរញ្ញវត្ថុផងដែរ ។ សំខាន់ជាងនេះទៅទៀត អតិថិជនដែលមានចំណេះដឹងផ្នែកហិរញ្ញវត្ថុ អាចប្រើប្រាស់នូវសិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួនដើម្បីពិភាក្សា និងចរចាជាមួយអ្នកផ្តល់សេវាហិរញ្ញវត្ថុ ។ គួរកត់សម្គាល់ថា ស្របពេលដែលធនាគារជាតិនៃកម្ពុជាបាននិងកំពុងរៀបចំនូវសន្និសីទនិងសិក្ខាសាលាជាបន្តបន្ទាប់ ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងរបស់សាធារណជន គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុកាន់តែច្រើន បានផ្សារភ្ជាប់នូវចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅនឹងផលិតផលឬសេវារបស់ខ្លួន ។ គំរូនៃការអនុវត្តល្អរបស់ប្រទេសមួយចំនួនបង្ហាញថា ការបញ្ចូលការអប់រំផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាថ្នាក់ជាតិ គឺជាយន្តការសំខាន់ក្នុងការបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុឲ្យបានទូលំទូលាយទូទាំងប្រទេស ។

ការមានចំណេះដឹងផ្នែកហិរញ្ញវត្ថុមិនអាចធានាបាននូវការផ្តល់សេវាហិរញ្ញវត្ថុដែលស្មើភាព និងមានការការពារគ្រប់គ្រាន់ដល់អតិថិជនឡើយ ។ ការណ៍នេះទាមទារឲ្យមានការត្រួតពិនិត្យលើការអនុវត្តទីផ្សាររបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ជាពិសេសទាក់ទងនឹងកិច្ចការពារអតិថិជន ។ គួរបញ្ជាក់ថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួន បាននិងកំពុងអនុវត្តកិច្ចការពារអតិថិជនស្របតាមគោលការណ៍ SMART Campaign ។ លើសពីនេះ កាលពីខែកុម្ភៈ ឆ្នាំ២០១៥ កន្លងមក ធនាគារជាតិនៃកម្ពុជា និងសមាគមធនាគារនៅកម្ពុជា បានសហការដាក់ចេញរួចរាល់ហើយនូវក្រមប្រតិបត្តិធនាគារ ដែលមានគោលដៅចូលរួមចំណែកបង្កើនទំនុកចិត្តមកលើប្រព័ន្ធធនាគារតាមរយៈការបង្កើតជាយន្តការការពារអតិថិជន ជំរុញសង្គតភាព និងតម្លាភាពប្រតិបត្តិការធនាគារ និងពង្រឹងទំនាក់ទំនងល្អរវាងគ្រឹះស្ថានជាមួយនឹងអតិថិជន ។ ធនាគារជាតិនៃកម្ពុជា បាននិងកំពុងសហការជាមួយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិផងដែរ (IFC) ដើម្បីអនុវត្តគម្រោងរៀបចំក្របខ័ណ្ឌនៃកិច្ចការពារអតិថិជនផ្នែកហិរញ្ញវត្ថុនៅកម្ពុជា ក្នុងនោះជាជំហានដំបូង ការិយាល័យគាំពារអតិថិជននឹងត្រូវបង្កើតឡើងនិងដាក់ឲ្យស្ថិតក្រោមការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជាដែលជាអាជ្ញាធរត្រួតពិនិត្យ ។ ស្របពេលជាមួយគ្នា មន្ត្រីជំនាញធនាគារជាតិនៃកម្ពុជា ក៏បានរៀនសូត្រការអនុវត្តកិច្ចការពារអតិថិជន និងការត្រួតពិនិត្យលើការអនុវត្តទីផ្សារពីធនាគារកណ្តាលថៃ និងម៉ាឡេស៊ី ដើម្បីជាបច្ច័យដល់ការអភិវឌ្ឍក្របខ័ណ្ឌនេះផងដែរ ។ ជារួម ការអប់រំផ្នែកហិរញ្ញវត្ថុនិងការការពារអតិថិជនចូលរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកំពស់បរិយាប័ន្នហិរញ្ញវត្ថុ និងកាត់បន្ថយការកេងប្រវ័ញ្ចផ្នែកហិរញ្ញវត្ថុនិងបញ្ហាបំណុលវ័ន្តករ ហើយអាទិភាពទាំងពីរនេះគួរតែត្រូវបានអនុវត្តស្របគ្នា ។

## ៣.៤. ការផ្តល់ហិរញ្ញប្បទានវិស័យកសិកម្មនិងអចលនទ្រព្យ

វិស័យកសិកម្ម ជាសសរទ្រូងមួយក្នុងចំណោមសសរទ្រូងសំខាន់ៗនៃសេដ្ឋកិច្ចជាតិ ហើយត្រូវបានយកចិត្តទុកដាក់ជាពិសេសដោយរាជរដ្ឋាភិបាលកម្ពុជា ។ ទន្ទឹមនេះ ទស្សនៈវិស័យអភិវឌ្ឍន៍វិស័យកសិកម្ម ត្រូវបានកំណត់ជាផ្នែកមួយនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា ដែលក្នុងនោះការបង្កើនតម្លៃបន្ថែមនៃផលិតកម្ម និងការ

នាំចេញអង្ករ គឺជាគោលនយោបាយអទិភាព ១ នៃគោលនយោបាយអទិភាពទាំង ៤ ។ ទោះបីជាយ៉ាងនេះក៏ដោយ ដំណើរការនៃការផលិត និងការនាំចេញស្រូវអង្ករ ដោយរាប់បញ្ចូលពីការដាំដុះរហូតដល់ការនាំចេញ នៅតែប្រឈមនឹងបញ្ហាមួយចំនួនដូចជា ៖ ការយល់ដឹងអំពីការជ្រើសរើសពូជ និងការដាំស្រូវនៅមានកំណត់ ហេដ្ឋារចនាសម្ព័ន្ធនៅមានភាពទន់ខ្សោយ ការប្រើប្រាស់បច្ចេកទេសមានកម្រិតទាប ការប្រកួតប្រជែងជាមួយប្រទេសជិតខាងក្នុងតំបន់ ទីផ្សារនាំចេញមិនច្បាស់លាស់ ដើមទុននៅមានភាពខ្វះខាត ព្រមទាំងការចំណាយខ្ពស់ទាក់ទងនឹងថ្លៃដើមអគ្គិសនីនិងដឹកជញ្ជូន ។

ទាក់ទងនៅនឹងការខ្វះខាតដើមទុន ធនាគារជាតិនៃកម្ពុជា បានយកចិត្តទុកដាក់និងពិភាក្សាជាបន្តបន្ទាប់លើបញ្ហានេះ ដើម្បីស្វែងយល់ពីបញ្ហាប្រឈមនិងវិធីសាស្រ្តក្នុងការជំរុញការផ្តល់ហិរញ្ញប្បទានដល់កសិករដាំស្រូវ ម្ចាស់រោងម៉ាស៊ីនកិនស្រូវ និងអ្នកនាំចេញអង្ករ បើទោះជាកន្លងមក គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានផ្តល់កម្ចីយ៉ាងច្រើនទៅតាមមធ្យោបាយផ្សេងៗក៏ដោយ ។ ការផ្តល់ឥណទានរបស់គ្រឹះស្ថានធនាគារដល់វិស័យកសិកម្មមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំធៀបនឹងសំពៀតឥណទានសរុប ដោយកើនឡើងពី ៩,៦៩% ក្នុងឆ្នាំ២០១៣ ដល់ ១០,០០% ក្នុងឆ្នាំ២០១៤ និង ១០,១៩% ក្នុងឆ្នាំ២០១៥ ជាមួយនឹងបរិមាណសាច់ប្រាក់ចំនួន ៤.៩៧៧,៦៥ ពាន់លានរៀល ។ ជាមួយគ្នានេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការផ្តល់ឥណទានដល់វិស័យកសិកម្ម ក្នុងនោះ ៣៥,២៤% នៃសំពៀតឥណទានសរុប ស្មើនឹង ៤.៣១៤,៣៨ ពាន់លានរៀល ត្រូវបានផ្តល់ដល់វិស័យកសិកម្ម ។ បន្ថែមលើនេះ គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ បានកំណត់អតិថិជនគោលដៅយ៉ាងច្បាស់លាស់ក្នុងការផ្តល់ឥណទានដល់វិស័យកសិកម្ម ដែលក្នុងនោះធនាគារផ្តោតលើការផ្តល់ឥណទានខ្នាតធំដល់ម្ចាស់រោងម៉ាស៊ីនកិនស្រូវ និងក្រុមហ៊ុននាំចេញអង្ករ ខណៈដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផ្តោតលើការផ្តល់ឥណទានខ្នាតតូចដល់កសិករ ។

ចំពោះការផ្តល់ឥណទានដល់វិស័យអចលនទ្រព្យភាគច្រើនគឺផ្តល់ដោយគ្រឹះស្ថានធនាគារ ហើយឥណទាននេះមានការកើនឡើងគួរឲ្យកត់សម្គាល់ពីមួយឆ្នាំទៅមួយឆ្នាំ ។ ឥណទានដល់វិស័យអចលនទ្រព្យដោយរាប់បញ្ចូលនូវសកម្មភាពអចលនទ្រព្យ ការសាងសង់ និងការទិញផ្ទះសម្រាប់លំនៅឋាន បានស្រូបយកឥណទានប្រមាណ ១៩,៥៦% នៃសំពៀតឥណទានសរុប ច្រើនជាងឆ្នាំមុនដែលមានប្រមាណតែ ១៨,៤៤% ។ ប្រទេសកម្ពុជាត្រូវបានចាត់ថ្នាក់ជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប ដោយសារការកើនឡើងនៃចំណូលក្រុមគ្រួសារ ហើយការណ៍នេះក៏ជាកត្តាមួយដែលជំរុញឲ្យមានការកើនឡើងនៃតម្រូវការទិញផ្ទះសម្រាប់លំនៅឋានផងដែរ ។ តាមរយៈបទពិសោធន៍ដែលទទួលបាននាអំឡុងពេលវិបត្តិហិរញ្ញវត្ថុឆ្នាំ២០០៨ កន្លងមក គ្រឹះស្ថានធនាគារបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការផ្តល់កម្ចីដល់វិស័យនេះ ដោយពិនិត្យយ៉ាងហ្មត់ចត់នូវគោលបំណងនៃការខ្ចីប្រាក់ គុណភាពវត្ថុបញ្ចាំ ការប្រើប្រាស់ឥណទាន និងជាពិសេសសមត្ថភាពសងប្រាក់របស់អតិថិជន ។

## ៣.៥. ការកសាងសមត្ថភាពមន្ត្រីត្រួតពិនិត្យ

ក្នុងឆ្នាំ២០១៥ មន្ត្រីត្រួតពិនិត្យបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលរយៈពេលខ្លី នៅតាមបណ្តាប្រទេសអាស៊ាន ចិន ជប៉ុន កូរ៉េ តៃវ៉ាន់ សហរដ្ឋអាមេរិក និងនៅតាមប្រទេសមួយចំនួនទៀតនៅទ្វីបអឺរ៉ុប ដូចជា ៖ អាល្លឺម៉ង់ ស្វីស បារាំង ទួរគី និងសាធារណរដ្ឋឆែក ។ ពិសេសជាងនេះទៅទៀត មន្ត្រីត្រួតពិនិត្យមានឱកាសទទួលបានការបណ្តុះបណ្តាលរយៈពេល ៣ ខែ នៅអាជ្ញាធរត្រួតពិនិត្យសេវាហិរញ្ញវត្ថុជប៉ុន ក្រោមក្របខ័ណ្ឌរបស់មូលនិធិរូបិយវត្ថុអន្តរជាតិផងដែរ ។ ក្នុងគោលដៅអភិវឌ្ឍវិជ្ជាជីវៈ រយៈពេលវែង មន្ត្រីត្រួតពិនិត្យវ័យក្មេងមួយចំនួន បាននិងកំពុងបន្តការសិក្សាថ្នាក់ក្រោយឧត្តម នៅតាមសាកលវិទ្យាល័យ

មួយចំនួនក្នុងប្រទេសចិន ជប៉ុន អូស្ត្រាលី នូវែលហ្សេឡង់ និងសហរដ្ឋអាមេរិក ។ លើសពីនេះទៅទៀត ធនាគារជាតិនៃកម្ពុជា យកចិត្តទុកដាក់ជាអាទិភាពលើការបណ្តុះបណ្តាលជំនាញឯកទេសរបស់មន្ត្រីត្រួតពិនិត្យ ដែលបច្ចុប្បន្ន មួយផ្នែកនៃមន្ត្រីត្រួតពិនិត្យកំពុងបន្តការសិក្សាជំនាញត្រួតពិនិត្យធនាគារតាមប្រព័ន្ធ Online FSI Connect របស់វិទ្យាស្ថានស្ថិរភាពហិរញ្ញវត្ថុ (Financial Stability Institute) នៃធនាគារសម្រាប់ការទូទាត់អន្តរជាតិ (BIS) និងទទួលការបណ្តុះបណ្តាលមុខវិជ្ជាគណនេយ្យករ ជំនាញ ACCA (Association of Chartered Certified Accountants) ។ សម្រាប់ទិសដៅអនាគត ការពង្រឹងជំនាញឯកទេសនេះ នឹងត្រូវបន្តអនុវត្តជាប្រចាំនិងពង្រីកវិសាលភាពបន្ថែម ដើម្បីផ្តល់លទ្ធភាពឲ្យមន្ត្រីត្រួតពិនិត្យក៏ដូចជាមន្ត្រីសក្តានុពលផ្សេងទៀតអាចបន្តដុសខាត់សមត្ថភាពរបស់ខ្លួនជាបន្តបន្ទាប់ ។

មន្ត្រីជំនាញធនាគារជាតិនៃកម្ពុជា បានរៀបចំកម្មវិធីចែករំលែកបទពិសោធន៍ស្តីពីការត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងការអភិវឌ្ឍការិយាល័យព័ត៌មានឥណទានជូនមន្ត្រីជំនាញធនាគារកណ្តាលមីយ៉ាន់ម៉ា និងបានចែករំលែកការត្រៀមខ្លួនឈានទៅអនុវត្តតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (CIFRS) ជូនមន្ត្រីជំនាញធនាគារកណ្តាលឡាវ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឡាវ ។ ទន្ទឹមនឹងនេះ មន្ត្រីត្រួតពិនិត្យក៏ត្រូវបានអញ្ជើញឲ្យធ្វើទស្សនកិច្ចសិក្សា និងផ្លាស់ប្តូរបទពិសោធន៍នៃការត្រួតពិនិត្យជាមួយអាជ្ញាធរត្រួតពិនិត្យសេវាហិរញ្ញវត្ថុ និងធនាគារកណ្តាលនៃប្រទេសកូរ៉េ និងកោះតៃវ៉ាន់ ប្រទេសចិនផងដែរ ។ ក្នុងទិសដៅរៀនសូត្រការអភិវឌ្ឍបទប្បញ្ញត្តិទាក់ទងនឹងសន្ទនីយភាព ធនាគារជាតិនៃកម្ពុជាទទួលបានការចែករំលែកបទពិសោធន៍នៃការអនុវត្តក្របខ័ណ្ឌសន្ទនីយភាពថ្មី ពីមន្ត្រីជំនាញរបស់ធនាគារកណ្តាលថៃផងដែរ ។

## ៣.៦. កិច្ចសហប្រតិបត្តិការអន្តរជាតិ

ធនាគារជាតិនៃកម្ពុជា បាននិងកំពុងបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយធនាគារកណ្តាល និងអាជ្ញាធរត្រួតពិនិត្យក្នុងតំបន់និងអន្តរជាតិ ព្រមទាំងស្ថាប័នពាក់ព័ន្ធនានាក្នុងគោលបំណងរៀនសូត្រ និងផ្លាស់ប្តូរបទពិសោធន៍ ក៏ដូចជាសហការបំពេញបេសកកម្មការងារថ្មីៗ ។ កាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យបានចូលជាសមាជិកពេញលេញទី ៩៩ ក្នុងចំណោម ១២៣ ស្ថាប័ននៃប្រទេសជាសមាជិកចំនួន ៩៥ របស់សហព័ន្ធបរិយាប័ន្នហិរញ្ញវត្ថុ (AFI) ។ បច្ចុប្បន្ន មន្ត្រីជំនាញធនាគារជាតិនៃកម្ពុជា កំពុងចូលរួមពិភាក្សាក្នុងក្រុមការងារចំនួន ៦ របស់សហព័ន្ធនេះ ដើម្បីសិក្សាលើលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុរបស់សហគ្រាសធុនតូច និងមធ្យម និងកំណត់និយមន័យនិងសូចនាករសម្រាប់គុណភាពនៃបរិយាប័ន្នហិរញ្ញវត្ថុ ។

ក្នុងឆ្នាំ២០១៥ ធនាគារជាតិនៃកម្ពុជា បានចុះហត្ថលេខាព្រមព្រៀងសហការជាដៃគូជាមួយអង្គការ Good Return ដែលមានមូលដ្ឋាននៅប្រទេសអូស្ត្រាលី ដើម្បីរៀបចំយុទ្ធសាស្ត្រនិងផែនការសកម្មភាពក្នុងការកសាងសមត្ថភាពនិងចំណេះដឹងផ្នែកហិរញ្ញវត្ថុដល់មន្ត្រីត្រួតពិនិត្យក៏ដូចជាសាធារណជនទូទៅ ។ ធនាគារជាតិនៃកម្ពុជា កំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រុមការងាររបស់អង្គការនេះ ក្នុងការរៀបចំធ្វើយុទ្ធនាការលើកកម្ពស់ការយល់ដឹងផ្នែកហិរញ្ញវត្ថុ ។ ទន្ទឹមនឹងនេះ បន្ទាប់ពីសហការបង្កើតការិយាល័យព័ត៌មានឥណទានដោយជោគជ័យ ធនាគារជាតិនៃកម្ពុជា កំពុងធ្វើការជាមួយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) បន្តទៀត ដើម្បីអនុវត្តគម្រោងរៀបចំក្របខ័ណ្ឌនៃកិច្ចការពារអតិថិជនផ្នែកហិរញ្ញវត្ថុនៅកម្ពុជា ។ ក្រោមក្របខ័ណ្ឌនៃកម្មវិធី Shaping Inclusive Finance Transformation (SHIFT) នៅកម្ពុជា ធនាគារជាតិនៃកម្ពុជាក្នុងនាមជាប្រធានក្រុមការងារអន្តរក្រសួង ដែលមានសមាជិកមកពីក្រសួងពាក់ព័ន្ធចំនួន ១២ បាននិងកំពុងដឹកនាំក្រុមការងារដើម្បីរៀបចំយុទ្ធសាស្ត្របរិយាប័ន្នហិរញ្ញវត្ថុដោយសហការជាមួយមូលនិធិអភិវឌ្ឍន៍មូលធនរបស់អង្គការសហប្រជាជាតិ UNCDF ។

## ឧបសម្ព័ន្ធ១

### ទិន្នន័យរបស់គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជាឆ្នាំ២០១៥
(ជាភាសាអង់គ្លេស)

## ឧបសម្ព័ន្ធ២

### បញ្ជីឈ្មោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

(សូមមើលនៅឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២ ផ្នែកភាសាអង់គ្លេស)

## ឧបសម្ព័ន្ធ៣

### អត្រាការប្រាក់លើប្រាក់បញ្ញើនិងឥណទាន ជាប្រាក់រៀលនិងរូបិយប័ណ្ណ

## ឧបសម្ព័ន្ធ៤

### ប្រព័ន្ធធនាគារកម្ពុជា

# ឧបសម្ព័ន្ធ ៣ ក

## អត្រាការប្រាក់លើការឲ្យខ្ចីចងការ (ប្រាក់រៀល និងរូបិយប័ណ្ណ)

(ប្រចាំខែធ្នូ ឆ្នាំ២០១៥)

(អត្រាប្រចាំឆ្នាំ)

| ល.រ | ឈ្មោះធនាគារ | ឥណទានជារៀល | | | | ឥណទានជាដុល្លារ | | | | ឥណទានជារូបិយប័ណ្ណផ្សេងៗ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១ខែ | ៣ខែ | ៦ខែ | ១២ខែ | ១ខែ | ៣ខែ | ៦ខែ | ១២ខែ | ១ខែ | ៣ខែ | ៦ខែ | ១២ខែ |
| 1 | ធនាគារ អេស៊ីលីដា | | | | 15.6% | | | | 10.0% | | | | 15.6% |
| 2 | ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ | | | | | 14.0% | 15.0% | 16.0% | 18.0% | | | | |
| 3 | ធនាគារ អាហ្វ្រីប៊ែង សាខាកម្ពុជា | 16.8% | 16.8% | 16.8% | 16.8% | 10.0% | 10.0% | 10.0% | 10.0% | | | | |
| 4 | ធនាគារ អេ អ៊ិន ហ្សេត រ៉ូយ៉ាល់ កម្ពុជា | | | | | | | | 6.9% | | | | |
| 5 | ធនាគារ បាងកក មហាជន ទទួលខុសត្រូវមានកម្រិត សាខាកម្ពុជា | 0.0% | 0.0% | 0.0% | 0.0% | 0.0% | 0.0% | 0.0% | 0.0% | | | | |
| 6 | ធនាគារ អភិវឌ្ឍន៍និងវិនិយោគកម្ពុជា ភីអិលស៊ី | | | | | 9.5% | 9.5% | 9.5% | 9.5% | | | | |
| 7 | ធនាគារ ចិន សាខាភ្នំពេញ | | | | | | | | 11.0% | | | | |
| 8 | ធនាគារ ឥណ្ឌា សាខាភ្នំពេញ | | | | | | | | 12.0% | | | | |
| 9 | ធនាគារ ប៊ូយ៉ុងខ្មែរ | | | | | | | | 9.0% | | | | |
| 10 | ធនាគារ កម្ពុជាអាស៊ី ចំកាត់ | | | | | | | | 12.0% | | | | |
| 11 | ធនាគារ មេគង្គកម្ពុជា | | | | | | | | | | | | |
| 12 | ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ | | | 28.6% | 28.6% | | | | | | | | |
| 13 | ធនាគារ កម្ពុជាពាណិជ្ជ ចំកាត់ | | | | | | | | 10.0% | | | | 10.0% |
| 14 | ធនាគារ កម្ពុជាសាធារណៈ ចំកាត់ | | | | | 10.0% | 10.0% | 10.0% | 10.0% | | | | |
| 15 | ធនាគារ កាណាឌីយ៉ា ចំកាត់ | | | | | | | | 13.2% | | | | |
| 16 | ធនាគារ កាថេយូណៃធីតកម្ពុជា ចំកាត់ | | | | | | | | 9.0% | | | | |
| 17 | ធនាគារ ស៊ី អាយ អ៊ឹម ប៊ី | | | | | 12.0% | 12.0% | 12.0% | 12.0% | | | | |
| 18 | ធនាគារ ពាណិជ្ជទីមួយ | | | | | | | | 11.0% | | | | |
| 19 | ធនាគារ ពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា | 18.0% | 18.0% | 18.0% | 18.0% | 18.0% | 18.0% | 18.0% | 18.0% | | | | |
| 20 | ធនាគារ ហុងលីអុង ខេមបូឌា ភីអិលស៊ី | | | | | | | | 10.0% | | | | |
| 21 | ធនាគារ អាយ ស៊ី ប៊ី ស៊ី | | | | | | | | 3.1% | | 3.5% | | 5.2% |
| 22 | ធនាគារ គូកមីន កម្ពុជា ភីអិលស៊ី | | | | | 14.0% | 14.0% | 14.0% | 14.0% | | | | |
| 23 | ធនាគារ ក្រុងថៃមហាជន ចំកាត់ | | | | | | | | 13.0% | | | | 10.0% |
| 24 | ម៉ារ៉ូហាន់ ធនាគារជប៉ុន ភី អិល ស៊ី | | | | 12.0% | | | | 11.0% | | | | |
| 25 | ធនាគារ មេយប៊ែង | | | | | | | | 10.3% | | | | |
| 26 | ធនាគារ អ៊ឹម ប៊ី | | | | | 10.3% | 10.3% | 10.3% | 10.3% | | | | |
| 27 | ធនាគារ មេហ្គាអ៊ីនធើណេសិនណល ខមមើសល | | | | | | | | 8.0% | | | | |
| 28 | ធនាគារ ហ្វីលីព ភីអិលស៊ី | | | | | | | | 12.0% | | | | |
| 29 | ធនាគារ ភ្នំពេញពាណិជ្ជ | | | | | | | | 16.0% | | | | |
| 30 | ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា | | | | | | | | 14.0% | | | | |
| 31 | ធនាគារ សាខម | | | | | | | 10.5% | 9.0% | | | | |
| 32 | ធនាគារ អេស ហេដ ប៊ី ភីអិលស៊ី សាខាភ្នំពេញ | | | | | | | | 6.5% | | | | |
| 33 | ធនាគារ ស៊ិនហាន ខ្មែរ | | | | | 15.0% | 15.0% | 15.0% | 15.0% | | | | |
| 34 | ធនាគារ តៃវ៉ាន់ ខូអបភើរេធីវ សាខាភ្នំពេញ | | | | | | | | 9.0% | | | | |
| 35 | ធនាគារ សហពាណិជ្ជ ក.អ | | | | | 15.0% | 15.0% | 15.0% | 15.0% | | | | |
| 36 | ធនាគារ វឌ្ឍនៈ | | | | | 13.2% | 13.2% | 13.2% | 13.2% | | | | |
| 37 | ធនាគារ ឯកទេស អានកូ | | | | | | | | 13.8% | | | | |
| 38 | ធនាគារ ឯកទេស អង្គរ កាពីតាល | | | | | | | | 13.0% | | | | |
| 39 | ធនាគារ ឯកទេស ខេមខាប់ភិថល ភីអិលស៊ី | | | | | | | | 24.0% | | | | |
| 40 | ធនាគារ ឯកទេស ខេមខូ លីមីតធីត | | | | | | | | 20.0% | | | | |
| 41 | ធនាគារ ឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី | | | | | | | 18.0% | 18.0% | | | | |
| 42 | ធនាគារ ឯកទេស វិនិយោគទីមួយ | | | | | | | | 20.4% | | | | |
| 43 | ធនាគារ ឯកទេស អកស៍ឡី វើលដ៍ប្រិជ ភីអិលស៊ី | | | | | | | | 9.2% | | | | |
| 44 | ធនាគារ ឯកទេស ភី អេច អែស អឹម អ៊ី ចំកាត់ | | | | | | | | 18.0% | | | | |
| 45 | ធនាគារ អភិវឌ្ឍន៍ជនបទ | | | | | | | | 9.0% | | | | |
| 46 | ធនាគារ ឯកទេស តូម៉ាតូ | | | | | | | | 13.0% | | | | |
| 47 | ធនាគារឯកទេស វីង (ខេមបូឌា) លីមីតធីត | | | | | | | | 13.0% | | | | |
| **មធ្យមភាគអត្រាការប្រាក់ក្រោយការថ្លឹង** | | **16.9%** | **16.9%** | **16.9%** | **15.7%** | **12.5%** | **12.6%** | **12.7%** | **11.3%** | | **0.0%** | | **0.0%** |
| **មធ្យមភាគអត្រាការប្រាក់** | | **17.4%** | **17.4%** | **21.1%** | **18.2%** | **12.8%** | **12.9%** | **13.2%** | **12.3%** | | **3.5%** | | **10.2%** |

## ឧបសម្ព័ន្ធ ៣ ខ

# អត្រាការប្រាក់លើប្រាក់បញ្ញើ ( ប្រាក់រៀល និងរូបិយប័ណ្ណ )

(ប្រចាំខែធ្នូ ឆ្នាំ២០១៥)

(អត្រាប្រចាំឆ្នាំ)

| ល.រ | ឈ្មោះធនាគារ | ប្រាក់បញ្ញើជារៀល | | | | | ប្រាក់បញ្ញើជាដុល្លារ | | | | | ប្រាក់បញ្ញើជារូបិយប័ណ្ណផ្សេងៗ | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សំចៃ | ប្រាក់បញ្ញើមានកាលកំណត់ | | | | សំចៃ | ប្រាក់បញ្ញើមានកាលកំណត់ | | | | សំចៃ | ប្រាក់បញ្ញើមានកាលកំណត់ | | | |
| | | | ១ខែ | ៣ខែ | ៦ខែ | ១២ខែ | | ១ខែ | ៣ខែ | ៦ខែ | ១២ខែ | | ១ខែ | ៣ខែ | ៦ខែ | ១២ខែ |
| 1 | ធនាគារ អេស៊ីលីដា | 1.3% | 3.0% | 5.0% | 6.0% | 7.0% | 0.5% | 1.5% | 2.5% | 3.8% | 5.0% | 0.2% | 0.5% | 1.5% | 2.3% | 3.3% |
| 2 | ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ | 0.8% | | | | | 0.8% | 2.3% | 3.3% | 4.3% | 5.3% | | | | | |
| 3 | ធនាគារ អាហ្វ្រីប៊ែង សាខាកម្ពុជា | 1.3% | 3.0% | 4.0% | 4.3% | 5.3% | 0.5% | 1.0% | 3.0% | 3.3% | 4.2% | | | | | |
| 4 | ធនាគារ អេ អ៊ិន ហ្សេត រ៉ូយ៉ាល់ កម្ពុជា | | 3.3% | 3.5% | 4.0% | 5.5% | 1.0% | 0.9% | 1.1% | 2.1% | 3.0% | | | | | |
| 5 | ធនាគារ បាងកក មហាជន ទទួលខុសត្រូវមានកម្រិត សាខាកម្ពុជា | 0.0% | 0.0% | 0.0% | 0.0% | 0.0% | 0.0% | 0.0% | 0.0% | 0.0% | 0.0% | 0.0% | 0.0% | 0.0% | 0.0% | 0.0% |
| 6 | ធនាគារ អភិវឌ្ឍន៏និងវិនិយោគកម្ពុជា ភីអិលស៊ី | | 3.6% | 4.6% | 5.6% | 6.5% | 0.8% | 2.3% | 3.0% | 4.3% | 5.3% | | | | | |
| 7 | ធនាគារ ចិន សាខាភ្នំពេញ | 0.1% | 0.1% | 0.1% | 0.1% | 0.1% | 0.5% | 1.3% | 2.3% | 2.8% | 3.3% | 0.4% | 1.5% | 3.3% | 3.2% | 3.0% |
| 8 | ធនាគារ ឥណ្ឌា សាខាភ្នំពេញ | | | | | | 0.8% | 1.0% | 2.3% | 3.0% | 4.0% | | | | | |
| 9 | ធនាគារ ប៊ូយ៉ុងខ្មែរ | 1.0% | 3.0% | 4.0% | 5.0% | 6.0% | 0.5% | 1.5% | 2.5% | 3.0% | 3.5% | | | | | |
| 10 | ធនាគារ កម្ពុជាអាស៊ី ចំកាត់ | | | | | | 2.0% | 2.5% | 3.8% | 4.8% | 5.8% | | | | | |
| 11 | ធនាគារ មេគង្គកម្ពុជា | 3.8% | | | | 8.0% | 2.0% | | 2.8% | 3.5% | 4.0% | | | | | |
| 12 | ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ | 2.0% | 3.0% | 4.0% | 5.0% | 7.0% | 1.3% | 2.0% | 3.0% | 4.0% | 6.0% | 2.0% | 3.0% | 4.0% | 5.0% | 7.0% |
| 13 | ធនាគារ កម្ពុជាពាណិជ្ជ ចំកាត់ | 0.1% | | 1.0% | 1.0% | 1.0% | 0.1% | | 1.0% | 1.0% | 1.0% | 0.1% | | 1.0% | 1.0% | 1.0% |
| 14 | ធនាគារ កម្ពុជាសាធារណៈ ចំកាត់ | 0.5% | 1.0% | 1.3% | 1.8% | 2.5% | 0.5% | 1.5% | 2.3% | 3.3% | 4.0% | 0.5% | | | | |
| 15 | ធនាគារ កាណាឌីយ៉ា ចំកាត់ | 2.0% | | 5.0% | 6.0% | 7.0% | 0.8% | 2.0% | 2.5% | 3.5% | 4.8% | 0.3% | 1.0% | 1.5% | 2.0% | 2.5% |
| 16 | ធនាគារ កាថេយូណៃធីតកម្ពុជា ចំកាត់ | | | | | | 0.5% | | 2.5% | 3.0% | 4.0% | | | | | |
| 17 | ធនាគារ ស៊ី អាយ អ៊ឹម ប៊ី | | | | | | 1.5% | 1.5% | 2.3% | 3.3% | 4.0% | | 2.5% | 3.5% | 4.3% | 5.0% |
| 18 | ធនាគារ ពាណិជ្ជទីមួយ | | | | | | 0.4% | 1.3% | 1.5% | 2.0% | 3.0% | | | | | |
| 19 | ធនាគារ ពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា | 1.5% | 3.0% | 5.0% | 6.0% | 7.0% | 0.8% | 1.5% | 2.5% | 3.8% | 5.0% | | | | | |
| 20 | ធនាគារ ហុងលីអុង ខេមបូឌា ភីអិលស៊ី | 1.0% | | | | | 0.8% | 1.8% | 2.5% | 3.8% | 4.8% | | | | | |
| 21 | ធនាគារ អាយ ស៊ី ប៊ី ស៊ី | | | | | | 0.5% | 1.5% | 2.3% | 3.0% | 3.5% | | | 2.9% | 3.0% | 3.1% |
| 22 | ធនាគារ គូកមីន កម្ពុជា ភីអិលស៊ី | 0.7% | 1.7% | 2.5% | 3.2% | 3.6% | 0.5% | 1.2% | 2.0% | 2.7% | 3.1% | | | | | |
| 23 | ធនាគារ ក្រុងថៃមហាជន ចំកាត់ | | | | | | 0.1% | | 0.5% | 0.8% | 1.0% | | | | | |
| 24 | ម៉ារ៉ូហាន់ ធនាគារជប៉ុន ភី អិល ស៊ី | 3.0% | 1.0% | 2.0% | 3.0% | 4.5% | 3.0% | 1.0% | 2.0% | 3.0% | 4.5% | | | | | |
| 25 | ធនាគារ មេយប៊ែង | | | | | | 1.5% | 2.5% | 3.0% | 4.0% | 5.0% | | | | | |
| 26 | ធនាគារ អ៊ីម ប៊ី | 0.8% | 3.5% | 4.5% | 5.0% | 6.0% | 0.5% | 2.8% | 3.2% | 4.2% | 5.0% | | | | | |
| 27 | ធនាគារ មេហ្គាអ៊ិនធើណេសិនណល ខមមើសល | 0.3% | | | | | 0.0% | 1.0% | 1.3% | 0.4% | 0.7% | | | | | |
| 28 | ធនាគារ ហ្វីលីព ភីអិលស៊ី | | | | | | 1.0% | 2.3% | 3.0% | 4.3% | 5.5% | | | | | |
| 29 | ធនាគារ ភ្នំពេញពាណិជ្ជ | | | | | | 2.6% | 2.5% | 4.0% | 5.0% | 6.0% | | | | | |
| 30 | ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា | 1.5% | 3.5% | 4.0% | 5.0% | 6.0% | 1.5% | 2.0% | 2.5% | 3.5% | 4.8% | | | | | |
| 31 | ធនាគារ សាខម | 1.0% | 2.3% | 3.0% | 3.5% | 5.3% | 0.5% | 2.3% | 3.0% | 3.5% | 5.3% | | | | | |
| 32 | ធនាគារ អេស ហេដ ប៊ី ភីអិលស៊ី សាខាភ្នំពេញ | | 2.9% | 3.8% | 5.5% | 5.5% | | 3.8% | 4.8% | 4.9% | 5.8% | | | | | |
| 33 | ធនាគារ ស៊ិនហាន ខ្មែរ | | | | | | 0.3% | 1.3% | 2.3% | 3.5% | 4.3% | | | | | |
| 34 | ធនាគារ តៃវ៉ាន់ ខូអបភើរេធីវ សាខាភ្នំពេញ | | | | | | 0.1% | 0.2% | 0.3% | 0.6% | 1.0% | | | | | |
| 35 | ធនាគារ សហពាណិជ្ជ ក.អ | 0.8% | | | | | 1.0% | 2.6% | 3.6% | 4.0% | 5.0% | 0.2% | 0.3% | 0.4% | 0.4% | 0.5% |
| 36 | ធនាគារ វឌ្ឍនៈ | 0.5% | 1.5% | 2.0% | 3.0% | 3.5% | 0.5% | 1.5% | 2.0% | 3.0% | 3.5% | | | | | |
| 37 | ធនាគារ ឯកទេស អានកូ | | | | | | | | | | | | | | | |
| 38 | ធនាគារ ឯកទេស អង្គរ កាពីតាល | | | | | | | | | | | | | | | |
| 39 | ធនាគារ ឯកទេស ខេមខាប់ភិថល ភីអិលស៊ី | | | | | | | | | | | | | | | |
| 40 | ធនាគារ ឯកទេស ខេមខូ លីមីតធីត | | | | | | | | | | | | | | | |
| 41 | ធនាគារ ឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី | | | | 10.0% | 8.3% | | | | | | | | | | |
| 42 | ធនាគារ ឯកទេស វិនិយោគទីមួយ | | | | | | | | | | | | | | | |
| 43 | ធនាគារ ឯកទេស អកស័ទ្បី វើលដ៍ប្រ៊ីដ ភីអិលស៊ី | | | | 10.0% | 8.3% | | | | | | | | | | |
| 44 | ធនាគារ ឯកទេស ភី អេច អែស អឹម អ៊ី ចំកាត់ | | | | | | | | | | | | | | | |
| 45 | ធនាគារ អភិវឌ្ឍន៏ជនបទ | 1.5% | 3.5% | 4.0% | 5.0% | 6.0% | 1.0% | 3.0% | 3.5% | 4.0% | 5.0% | | | | | |
| 46 | ធនាគារ ឯកទេស តូម៉ាតូ | | | | | | | | | | | | | | | |
| 47 | ធនាគារឯកទេស វីង (ខេមបូឌា) លីមីតធីត | | | | | | | | | | | | | | | |
| | **មធ្យមភាគអត្រាការប្រាក់ក្រោយការថ្លឹង** | **1.2%** | **2.4%** | **3.8%** | **4.6%** | **5.6%** | **0.8%** | **1.7%** | **2.5%** | **3.4%** | **4.5%** | **12.4%** | **0.3%** | **0.9%** | **1.7%** | **2.2%** |
| | **មធ្យមភាគអត្រាការប្រាក់** | **1.2%** | **2.5%** | **3.3%** | **4.7%** | **5.4%** | **0.9%** | **1.8%** | **2.5%** | **3.2%** | **4.1%** | **0.5%** | **1.5%** | **2.3%** | **2.6%** | **3.2%** |

# ឧបសម្ព័ន្ធ ៤

## ប្រព័ន្ធធនាគារកម្ពុជា

*ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥*

### ធនាគារជាតិនៃកម្ពុជា

### ៣៦ ធនាគារពាណិជ្ជ

#### ១០ សាខាធនាគារបរទេស

១-ធនាគារ កសិកកម្ម និងអភិវឌ្ឍន៍ជនបទវៀតណាម សាខាកម្ពុជា
២-ធនាគារ បាងកក មហាជន ទទួលខុសត្រូវមានកម្រិត សាខាកម្ពុជា
៣-ធនាគារ ចិន សាខាភ្នំពេញ
៤-ធនាគារឥណ្ឌាសាខាភ្នំពេញ
៥-ធនាគារ ពាណិជ្ជ ទី១ សាខាភ្នំពេញ
៦-ធនាគារ អាយ ស៊ី ប៊ី ស៊ី លីមីតធីត សាខាភ្នំពេញ
៧-ធនាគារ ក្រុងថៃចំកាត់ (មហាជន)
៨-ធនាគារ អ៊ឹបមី ភីអិលស៊ី សាខាភ្នំពេញ កម្ពុជា
៩-ធនាគារ មេហ្គា អ៊ិនធើណេសិនណល ខមមើសល សាខាភ្នំពេញ
១០-ធនាគារ តៃវ៉ាន់ ខូអបភើរេធីវ សាខាភ្នំពេញ

#### ១២ បង្កើតឡើងក្នុងស្រុក

១-ធនាគារ អេស៊ីលីដា ភីអិលស៊ី
២-ធនាគារ វឌ្ឍនៈអាស៊ីចាំកាត់
៣-ធនាគារ វិនិយោគនិងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី
៤-ធនាគារ ប៉ូយុងខ្មែរ
៥-ធនាគារ កម្ពុជាអាស៊ី
៦-ធនាគារ កម្ពុជាមេគង្គ មហាជន ទទួលខុសត្រូវមានកំរិត
៧-ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ
៨-ធនាគារ កាណាឌីយ៉ា ក.អ
៩-ធនាគារ ពាណិជ្ជកម្មក្រៅប្រទេស
១០-ម៉ារូហាន់ ធនាគារ ជប៉ុន ភីអិលស៊ី
១១-ធនាគារ ភ្នំពេញពាណិជ្ជ
១២-ធនាគារ វឌ្ឍនៈ

#### ១៤ បុត្តសម្ព័ន្ធធនាគារ

១-ធនាគារ អេអ៊ិនហ្សែត រ៉ូយ៉ាល់
២-ធនាគារ កម្ពុជាពាណិជ្ជ
៣-ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី
៤-ធនាគារ កាថេយូណៃធីតកម្ពុជា ចំកាត់
៥-ធនាគារ ស៊ី អាយ អ៊ឹមប៊ី ភីអិលស៊ី
៦-ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី
៧-ធនាគារ គូកមីន កម្ពុជា ភីអិលស៊ី
៨-ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី
៩-ធនាគារ ហ្វីលីព ភីអិលស៊ី
១០-ធនាគារ អ អេច ប៊ី ឥណ្ឌូឆាយណា
១១-ធនាគារ សាយហ្គនធឿងទីន (ខេមបូឌា) ភីអិលស៊ី
១២-ធនាគារ អេស ហេជ ប៊ី ភីអិលស៊ី
១៣-ធនាគារ ស៊ិនហានខ្មែរ
១៤-ធនាគារ សហពាណិជ្ជ ក.អ

### ១២ ធនាគារឯកទេស

#### ១ ធនាគាររដ្ឋ

១-ធនាគារឯកទេស អភិវឌ្ឍន៍ជនបទ

#### ១១ ធនាគារឯកជន

១-ធនាគារឯកទេសអ៊ីអន(ខេមបូឌា) ភីអិលស៊ី
២-ធនាគារឯកទេស អានកូ
៣-ធនាគារឯកទេស អង្គរ កាពីតាល
៤-ធនាគារឯកទេស ខេម ខាប់ភីថល ភីអិលស៊ី
៥-ធនាគារឯកទេស ខេមខូ
៦-ធនាគារឯកទេស ឈីហ្វ (ខេមបូឌា) ភីអិលស៊ី
៧-ធនាគារឯកទេស វិនិយោគទី១
៨-ធនាគារឯកទេស អកស៍ឡឺវើលដ៏ប្រ៊ិដ ភីអិលស៊ី
៩-ធនាគារឯកទេស ភី អេច អែស អ៊ឹម អ៊ី ចំកាត់
១០-ធនាគារឯកទេស តូមាតូ
១១-ធនាគារឯកទេស វីង(ខេមបូឌា) លីមីតធីត

### ៨ ការិយាល័យតំណាង

១-ធនាគារវិនិយោគនិងអភិវឌ្ឍន៍នៃវៀតណាម
២-ធនាគារប៊ែង អហ្វ តូក្យូ មីតស៊ុយប៊ីស៊ី
៣- ធនាគារ អ៊ិនដាស ស្រៀល ប៊ែង អហ្វ ខូរៀ
៤- ធនាគារ កសិកន ផាប់ប្លីក ខមភេនី លីមីធីត
៥-ធនាគារមីហ៊្សូហូ
៦-ធនាគារ សៀង ហៃ ខមមែសល & សវីង
៧-ធនាគារ ស្តង់ដារឆាទីរ៉េត
៨-ធនាគារស៊ូមីតូម៉ូមីតស៊ុយ ប៊ែងឃីងខបភើរេសិន

## ៥៨ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

### ៥០ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

១-អាក់ទីវ ភីភល ភីអិលស៊ី
២-អង្គរ អេស៊ីអ៊ី ស្តារ ក្រេឌីត លីមីធីត
៣-អេផល ហ្វាយនែន ភីអិលស៊ី
៤-អេស៊ាន ផេស៊ីហ្វិក ហ្វាយនែន ភីអិលស៊ី
៥-ប៉ៃមប៊ូ ហ្វាយនែន ភីអិលស៊ី
៦-បាយ៉ន ក្រេឌីត លីមីតធីត
៧-បរិបូរណ៍ ភីអិលស៊ី
៨-ខេមបូឌា ឡេប៊ីរយៃរ៍ ភីអិលស៊ី
៩-ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត
១០-សៃលកាត ហ្វាយនែន ភីអិលស៊ី
១១-សេនជូរី ខេមបូ ឌីវេឡុបមេន ភីអិលស៊ី
១២-ចំរើន ម៉ាយក្រូហ្វាយនែន លីមីធីត
១៣-ស៊ីធី ភីអិលស៊ី
១៤-ខឹលេកធីវ វីន (ខេមបូឌា) ភីអិលស៊ី
១៥-ឌៃលតា ម៉ាយក្រូហ្វាយនែន ភីអិលស៊ី
១៦-ឥណទានអភិវឌ្ឍន៍ប្រជាជន លីមីតធីត
១៧-ហ្វាមើរ  ហ្វាយនែន អិលធីឌី
១៨-សមាគមមូលនិធិសហភាពអភិវឌ្ឍន៍កសិករ
១៩-ហ្វឹស ហ្វាយនែន ភីអិលស៊ី
២០-ហ្វូណនមីក្រូហ្វាយនែន
២១-ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី
២២-ហ្វ្រីន សេនត្រល ម៉ាក្រូហ្វាយនែន អិលធីឌី
២៣-ឥណទានពលរដ្ឋរុងរឿង អិលធីឌី
២៤-ខេប៊ីអេសស៊ី(ខេមបូឌា)ភីអិលស៊ី
២៥-ឃី ភីអិលស៊ី
២៦-ខេមរៈ លីមីធីត
២៧-លី ហួរ ភីអិលស៊ី
២៨-មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី
២៩-អមតៈ ខាប់ភីថល ភីអិលស៊ី
៣០-មហានគរ មីក្រូហិរញ្ញវត្ថុ  ភីអិលស៊ី
៣១-និរន្តរ មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី
៣២-អ្វូរ៉ូ ហ្វាយនែន ខប ភីអិលស៊ី
៣៣-ពិភពថ្មី មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី
៣៤-ប្រាយម៍ អិមអេហ្វ អិលធីឌី
៣៥-ព្រីនស៍មីក្រូហ្វាយនែន
៣៦-រ៉ូយ៉ាល់ម៉ាយក្រូហ្វាយនែន ភីអិលស៊ី
៣៧-សច្ចៈ ម៉ាយក្រូហ្វាយនែន ភីអិលស៊ី
៣៨-សហគ្រិនភាព អេសធី ម៉ាយក្រូ ហ្វាយនែន ភីអិលស៊ី
៣៩-សាមគ្គី មីក្រូហ្វាយនែន អ៊ីនស៊ីធ្យូសិន ភីអិលស៊ី
៤០-សម្បត្តិ ហ្វាយនែន ភីអិលស៊ី
៤១-សាមិក ភីអិលស៊ី
៤២-សម្ព័ន្ធសគមន៍សហគ្រាសធុនតូច និងមធ្យម
៤៣-សំរិទ្ធិស័ក មីក្រូហិរញ្ញវត្ថុ លីមីតធីត
៤៤-សីលានិធិ  លីមីតធីត
៤៥-សិរីឧត្តម មីក្រូហិរញ្ញវត្ថុ  ភីអិលស៊ី
៤៦-សូណាត្រា ភីអិលស៊ី
៤៧-តាកា ម៉ាយក្រូហ្វាយនែន ភីអិលស៊ី
៤៨-ធីប៊ីប៊ី (ខេមប៊ូឌា) ភីអិលស៊ី
៤៩-អ៊ូរី ហ្វាយនែន ខេមបូឌា ភីអិលស៊ី
៥០-វ៉ាយស៊ីភី ម៉ាយក្រូហ្វាយនែន

### ៨ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ

១-អម្រឹត ខូអិលធីឌី
២-អង្គរមីក្រូហិរញ្ញវត្ថុ (កម្ពុជា)
៣-ហត្ថាកសិករ លីមីតធីត
៤-ក្រេឌីត ភីអិលស៊ី
៥-អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី
៦-ប្រាសាក់
៧-ស្ថាបនា លីមីតធីត
៨-វីសិនហ្វាន់ (ខេមបូឌា) អិលធីឌី

## ៩ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ

១- អេលីន លីស៊ីង ភីអិលស៊ី
២- ជីអិល ម៉ាយក្រូហ្វាយនែន ភីអិលស៊ី
៣- ខេខេហ្វាន់ លីស៊ីង ភីអិលស៊ី
៤- ឡឺរ៉ូស៊េ ហ្វាយនែនសល លីស៊ីង ភីអិលស៊ី
៥-មេហ្គា លីស៊ីង ភីអិលស៊ី
៦- អអិមអេ ហ្វាយនែនសល ស៊ើវីស (ខេមបូឌា) ភីអិលស៊ី
៧-សូស្តី ហ្វាយនែន ភីអិលស៊ី
៨-តូយ៉ូតា ស៊ុយស៊ូ ហ្វាយនែន (ខេមបូឌា) ភីអិលស៊ី
៩- ទ្រព្យខ្ញុំ លីស៊ីង ភីអិលស៊ី

## ២១ សាខាធនាគារជាតិនៅតាមខេត្ត

១-បាត់ដំបង
២-បន្ទាយមានជ័យ
៣-កំពង់ចាម
៤-កំពង់ឆ្នាំង
៥-កំពង់ស្ពឺ
៦-កំពង់ធំ
៧-កំពត
៨-កណ្តាល
៩-កោះកុង
១០-ក្រចេះ
១១-ក្រុងភ្នំពេញ
១២-មណ្ឌលគីរី
១៣-ព្រះវិហារ
១៤-ព្រៃវែង
១៥-ពោធិសាត់
១៦-រតនៈគីរី
១៧-សៀមរាប
១៨-ព្រះសីហនុ
១៩-ស្ទឹងត្រែង
២០-ស្វាយរៀង
២១-តាកែវ

១-ក្រុមហ៊ុនក្រេឌីតប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី

## អាជីវកម្មប្តូរប្រាក់

ភ្នំពេញៈ
-អាជ្ញាប័ណ្ណ ៧៥
-លិខិតអនុញ្ញាត ៤៧
ខេត្តៈ
-អាជ្ញាប័ណ្ណ ២
-លិខិតអនុញ្ញាត១.៨៨៦

## ៦ តតិយភាគី

១-ក្រុមហ៊ុន អាយ អឹម អ៊ី(អ៊ឹម) អែស ឌី អិន ប៊ីអេចឌី
២-ក្រុមហ៊ុន Money Gram Payment Systems, Inc.
៣-ក្រុមហ៊ុន ផេហ្គោស៊ី(ខេមបូឌា) ខូ អិលធីឌី
៤-ក្រុមហ៊ុន Smart Axiata co. Ltd
៥-ក្រុមហ៊ុន វៀតធេល(ខេមបូឌា) ភី ធីអ៊ី អិលធីឌី
៦- ក្រុមហ៊ុន Western Union Network (Ireland) Ltd.

# បញ្ជីឈ្មោះប្រគបគ្គករគេលលាទាន

## គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥

| ល.រ | ឈ្មោះអង្គការ-សមាគមមិនមែនរដ្ឋាភិបាល | ល.រ | ឈ្មោះអង្គការ-សមាគមមិនមែនរដ្ឋាភិបាល |
|---|---|---|---|
| ១ | សមាគមអភិវឌ្ឍន៍កសិករនិងទេសចរណ៍ | ២០ | សមាគមអភិវឌ្ឍន៍តំបន់ពាយ័ព្យ |
| ២ | សមាគមជួយកសិករ | ២១ | វិទ្យាស្ថានសន្តិភាពនិង អភិវឌ្ឍន៍ |
| ៣ | សមាគមផ្តើមគំនិតពាណិជ្ជកម្ម | ២២ | អង្គការអភិវឌ្ឍន៍សង្គមជនបទ |
| ៤ | សមាគមសំណាងអភិវឌ្ឍន៍ជនបទ | ២៣ | សមាគមអភិវឌ្ឍន៍សណ្តែកសៀងតាអុង |
| ៥ | ស៊ី អឹម ខេ | ២៤ | សមាគមអភិវឌ្ឍន៍ភូមិ |
| ៦ | អង្គការឥណទានលប់បំបាត់ភាពក្រីក្រ | ២៥ | ស៊ី ខេ អ៊ឹម អេហ្វ ជី ខេមបូឌា |
| ៧ | អង្គការបណ្តាញសេដ្ឋកិច្ចកម្ពុជា | ២៦ | អង្គការសប្បុរស |
| ៨ | អង្គការសង្គហអភិវឌ្ឍន៍កម្ពុជា | ២៧ | អង្គការ លោកគ្រូ |
| ៩ | អង្គការអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទនៅកម្ពុជា | ២៨ | អង្គការ ពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ |
| ១០ | សហព័ន្ធសហគមន៍សន្សំប្រាក់កម្ពុជា | ២៩ | អង្គការ សមាគមកសិករខ្មែរបាត់ដំបង |
| ១១ | អង្គការច័ន្ទសុខសាន្ត | ៣០ | អង្គការអភិវឌ្ឍន៍គ្រួសារក្រីក្រជាមួយប្រព័ន្ធកសិកម្មនៅប្រទេសកម្ពុជា |
| ១២ | អង្គការទ្រទ្រង់សមាគមបង្កើនអភិវឌ្ឍន៍ | ៣១ | សមាគម សុភា អភិវឌ្ឍន៍ |
| ១៣ | សមាគមជាតិទ្រទ្រង់កសិផល | ៣២ | អង្គការទីភ្នាក់ងារអភិវឌ្ឍន៍សេដ្ឋកិច្ចនិងការងារ |
| ១៤ | អង្គការអភិវឌ្ឍន៍របរចិញ្ចឹមជីវិតកសិករ | ៣៣ | អង្គការអភិវឌ្ឍន៍សហគមន៍ថ្មី |
| ១៥ | អង្គការអភិវឌ្ឍន៍ជនបទខ្មែរ | ៣៤ | អង្គការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងស្រុក |
| ១៦ | សមាគមសុខមាលភាពស្ត្រីខេត្តក្រចេះ | ៣៥ | សមាគម គឹម សាន ទ្រទ្រង់ជីវភាពកសិករ |
| ១៧ | អង្គការលូថេរ៉ានបំរើពិភពលោក | ៣៦ | អង្គការដៃគូ (អ.ដ.គ) |
| ១៨ | គម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទ | ៣៧ | អង្គការអភិវឌ្ឍន៍សេដ្ឋកិច្ចកសិករកម្ពុជា (អ.ស.ក.ក) |
| ១៩ | អង្គការក្រុមការងារសេដ្ឋកិច្ចថ្មី | ៣៨ | អង្គការមូលនិធីអភិវឌ្ឍន៍សហគមន៍ (អ.ម.អ.ស) |

| ល.រ | ឈ្មោះអង្គការ-សមាគមមិនមែនរដ្ឋាភិបាល | ល.រ | ឈ្មោះអង្គការ-សមាគមមិនមែនរដ្ឋាភិបាល |
|---|---|---|---|
| ៣៩ | អង្គការព្រះខ័ន | ៥៩ | អង្គការ រូបិយបណ្ណខ្មែរ |
| ៤០ | អង្គការទីភ្នាក់ងារអភិវឌ្ឍន៍មូលធនសហគមន៍ | ៦០ | អង្គការសម្ព័ន្ធធនធានមនុស្សនៃសកម្មភាពហិរញ្ញវត្ថុ |
| ៤១ | អង្គការឥណទានបៃតង | ៦១ | អង្គការដៃគូសហគមន៍ |
| ៤២ | អង្គការលើកស្ទួយសេដ្ឋកិច្ចគ្រួសាររីករាយ | ៦២ | អង្គការបាសាក់ |
| ៤៣ | អង្គការគ្រួសាររុងរឿង | ៦៣ | អង្គការដៃគូហិរញ្ញវត្ថុកម្ពុជា |
| ៤៤ | អង្គការវឌ្ឍនៈដៃគូអភិវឌ្ឍន៍សេដ្ឋកិច្ចសហគមន៍ | ៦៤ | អង្គការកូនខ្មែរ |
| ៤៥ | អង្គការសំឡាញ់ហិរញ្ញវត្ថុ | ៦៥ | អង្គការមានជ័យ |
| ៤៦ | អង្គការឥណទានវីហ្សា | ៦៦ | អង្គការអភិវឌ្ឍន៍សហគមន៍អានពិសិដ្ឋ |
| ៤៧ | អង្គការអភិវឌ្ឍន៍សហគមន៍ព្រះអាទិត្យ | ៦៧ | អង្គការប្រសើរ មូលនិធិអភិវឌ្ឍន៍សេដ្ឋកិច្ចសហគមន៍ |
| ៤៨ | អង្គការដៃគូហិរញ្ញវត្ថុ | ៦៨ | អង្គការលើកកម្ពស់ជីវភាពប្រជាជនកម្ពុជា |
| ៤៩ | អង្គការអណ្តែត | ៦៩ | អង្គការទីភ្នាក់ងារលើកកម្ពស់ជីវភាពគ្រួសារ |
| ៥០ | អង្គការឥណទានពលរដ្ឋកម្ពុជា | ៧០ | អង្គការសមធម៌អភិវឌ្ឍន៍សេដ្ឋកិច្ច |
| ៥១ | អង្គការឥណទានកម្ពុជា | ៧១ | អង្គការមូលនិធិសហគមន៍ |
| ៥២ | អង្គការបង្កើនជីវភាពសហគមន៍ | ៧២ | អង្គការសម្បត្តិសំរិទ្ធិ |
| ៥៣ | អង្គការឥណទានសួស្តី | ៧៣ | សមាគមរតនៈអភិវឌ្ឍន៍សេដ្ឋកិច្ច |
| ៥៤ | អង្គការពន្លឺឥណទាន | ៧៤ | អង្គការលើកកម្ពស់សេដ្ឋកិច្ចកសិករ |
| ៥៥ | ទីភ្នាក់ងារអភិវឌ្ឍន៍ឥណទានគ្រួសារ | ៧៥ | អង្គការមូលនិធិសុវណ្ណវឌ្ឍនៈអភិវឌ្ឍន៍សង្គម |
| ៥៦ | អង្គការគ្រួសារខ្មែរយើង | ៧៦ | សមាគមលើកកម្ពស់ជីវភាពសង្គម |
| ៥៧ | អង្គការ ការ៉ុត | ៧៧ | អង្គការទីភ្នាក់ងារឥណទានភូមិភាគឥសាននៃកម្ពុជា |
| ៥៨ | អង្គការ ម៉ី ជីង អភិវឌ្ឍន៍សហគមន៍ | ៧៨ | អង្គការសំណាងអភិវឌ្ឍន៍សេដ្ឋកិច្ច |

| ល.រ | ឈ្មោះអង្គការ-សមាគមមិនមែនរដ្ឋាភិបាល | ល.រ | ឈ្មោះអង្គការ-សមាគមមិនមែនរដ្ឋាភិបាល |
|---|---|---|---|
| ៧៩ | អង្គការអភិវឌ្ឍន៍សង្គមកម្ពុជា | ៩៩ | អង្គការអភិវឌ្ឍន៍កសិកម្មបៃតង |
| ៨០ | អង្គការដៃគូអភិវឌ្ឍន៍កម្ពុជា | ១០០ | អង្គការលើកកំពស់ជីវភាពគ្រួសារ |
| ៨១ | អង្គការឥណទាននៃកម្ពុជា | ១០១ | អង្គការឥណទានប្រសិទ្ធ |
| ៨២ | សមាគមឥណទានពលរដ្ឋខ្មែរ | ១០២ | សហគមឥណទាន ជំ សំណាង |
| ៨៣ | អង្គការជោគជ័យ | ១០៣ | អង្គការរៀលឥណទាន |
| ៨៤ | អង្គការលើកកំពស់ជីវភាពកសិករ | ១០៤ | អង្គការសេដ្ឋកិច្ចគ្រួសារកម្ពុជា |
| ៨៥ | សមាគមឥណទានសារីណា | ១០៥ | ក្រុមហ៊ុន ឥណទាន អ៊ីហ្សី ហ្វាយនែន ភីអិលស៊ី |
| ៨៦ | អង្គការស្រូវទុំ | ១០៦ | អង្គការសកម្មភាពដើម្បីការអភិវឌ្ឍ និងសុខភាព |
| ៨៧ | សមាគមអភិវឌ្ឍន៍កម្ពុជា | ១០៧ | អង្គការស្លឹកមាសខ្មែរ |
| ៨៨ | អង្គការពន្លឺខ្មែរហិរញ្ញវត្ថុ | ១០៨ | អង្គការ រិទ្ធីពិស័ក្កិកម្ពុជា ដើម្បីអភិវឌ្ឍន៍សង្គម |
| ៨៩ | អង្គការខ្មែរមូលធន | ១០៩ | អង្គការ សំណាងអភិវឌ្ឍន៍សហគមន៍ |
| ៩០ | អង្គការអមតៈ | | |
| ៩១ | អង្គការមូលនិធិកល្យាណមិត្ត | | |
| ៩២ | អង្គការសុខៈប្រជា | | |
| ៩៣ | អង្គការឥណទានតំបន់ | | |
| ៩៤ | អង្គការអភិវឌ្ឍន៍បៃតង | | |
| ៩៥ | អង្គការខ្មែរសម្រាប់ការអភិវឌ្ឍ | | |
| ៩៦ | អង្គការអភិវឌ្ឍន៍គ្រួសារ និងសហគមន៍ | | |
| ៩៧ | អង្គការចីរភាពហិរញ្ញវត្ថុ | | |
| ៩៨ | អង្គការរឹទ្ធ សុខា | | |